CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែមេសា ឆ្នាំទី៤ ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០១១ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ    លេខ ៤៤

## មាតិកា



**មានការងារ មាន ឯករាជ្យ តែមិន...**
**ទំព័រ ៥**



**សមាគមពន្លកថ្មី ផ្ដល់ទឹកស្អាត...**
**ទំព័រ ៧**



**ព្រឹទ្ធាចារ្យ: "អាចារ្យ គួរតែរៀនក្បួនខ្នាត"**
**ទំព័រ ១៧**

# កម្ពុជាជាប្រទេសកសិកម្ម តែឥណទាន ផ្តោតសម្រាប់ផ្នែកនេះនៅមានកម្រិត



កម្ពុជាគឺជាប្រទេសកសិកម្ម។ ប្រជាជន ៨០% រស់នៅដោយពឹងផ្អែកលើវិស័យនេះ។ ដូច្នេះវិស័យកសិកម្មចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ប៉ុន្តែវិស័យកសិកម្មអាចរីកចម្រើនទៅបានទាល់តែមានប្រភពទុនគ្រប់គ្រាន់។ តើអ្វីជាបញ្ហាប្រឈមរបស់កសិករដើម្បីទទួលបានឥណទានដើម្បីធ្វើការអភិវឌ្ឍន៍លើផ្ទៃដីរបស់ខ្លួន? **ទំព័រទី១០_១១**

កម្មវិធីវិទ្យុ

**អេម៉ានូអែល** **សំឡេងពីព្រះសហគមន៍កាតូលិក !**

**ភ្នំពេញ : FM 102.5 Mhz** ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
**បាត់ដំបង : FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
**សៀមរាប: FM 102.5 Mhz** ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
**កំពង់ធំ : FM 88.5 Mhz** ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
**កំពង់ចាម : FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
**ក្រុងព្រះសីហនុ : FM 107.5 Mhz** ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
**កំពត : FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ



Photo : L. Sovanna

តំណាងសាសនាព្រះពុទ្ធ គ្រីស្តសាសនាកាតូលិក ប្រូតេស្តង់ និងឥស្លាមក្នុងក្រុមអន្តរសាសនាកម្ពុជាចូលរួមរំលែកទុក្ខប្រជាជនជប៉ុននៅស្ថានទូតជប៉ុន-ភ្នំពេញ។



Photo : L. Sovanna

តំណាងសាសនាកាតូលិកក្នុងក្រុមអន្តរសាសនាកម្ពុជាចុះហត្ថលេខាលើសាររំលែកទុក្ខរបស់ខ្លួនកាលពីថ្ងៃទី២២ មីនា នៅស្ថានទូតជប៉ុនរាជធានីភ្នំពេញសម្រាប់ប្រជាជនជប៉ុនដែលបានស្លាប់ និងបាត់ខ្លួនរាប់ម៉ឺនយ៉ាងគួរឱ្យរន្ធត់ដោយគ្រោះមហន្តរាយធម្មជាតិការរញ្ជួយដី និងស៊ូណាមិ។

## ព្រះសហគមន៍កាតូលិកអធិដ្ឋានសម្រាប់ប្រជាជនជប៉ុន



Photo : V. Sambath

គ្រីស្តបរិស័ទ បព្វជិត បព្វជិតា អស់លោកបូជាចារ្យ និងលោកអភិបាលព្រះសហគមន៍កាតូលិកនៅកម្ពុជាទាំងអស់បានមកជួបជុំគ្នាក្រោមអធិបតីភាពរបស់លោកអគ្គអភិបាលជីអូវ៉ាន់នី ដានីញ៉ែលឡូ អគ្គរាជទូតបុរីវ៉ាទីកង់ប្រចាំប្រទេសកម្ពុជាដើម្បីធ្វើការអធិដ្ឋានចូលរួមរំលែកទុក្ខប្រជាជនជប៉ុន ដែលរងគ្រោះដោយសាររញ្ជួយដី និងរលកយក្សស៊ូណាមិ ។

ការអធិដ្ឋាននេះបានប្រព្រឹត្តិនៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) ទីក្រុងភ្នំពេញ ដោយមានការចូលរួមពីសំណាក់ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាផង ។

លោកអគ្គរាជទូតជីអូវ៉ាន់នី មានប្រសាសន៍ ក្នុងពិធី ថា សេចក្តីស្រឡាញ់ នាំឱ្យយើងមករួមគ្នាទីនេះ ជាគ្រួសារតែមួយ ។ សេចក្តីស្រឡាញ់នាំយើងឱ្យបានជិតស្និទ្ធជាមួយប្រជាជនជប៉ុន ។ សេចក្តីស្រឡាញ់ មិនមែនមនោសញ្ចេតនាទេ គឺជាព្រះយេស៊ូគ្រីស្ត ។

ចំណែកលោកអភិបាលអូលីវីយេ មានប្រសាសន៍ថា ក្នុងនាមជាអភិបាលព្រះសហគមន៍ សូមឱ្យបងប្អូនអង្វរដល់ព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់ ជាពិសេសជនជាតិជប៉ុន ។

លោកអគ្គរាជទូតជប៉ុនបានថ្លែងអំណរគុណព្រះសហគមន៍កាតូលិកដែលបង្ហាញនូវការចូលរួមទុក្ខព្រួយរួមជាមួយប្រជាជននៅពេលជួបបញ្ហាលំបាកយ៉ាងធ្ងន់ធ្ងរនោះ ។

**លី សុវណ្ណា**

# វិចារណកថា

## សូមជូនពរបងប្អូន និងសូមរិះគិតអំពីព្រះបន្ទូល



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

បងប្អូនជាទីស្រឡាញ់! សួស្តីឆ្នាំថ្មី !

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីខាងមុខ ! អ្នកនាំសារសូមជូនពរបងប្អូនសូមជួបតែសុភមង្គលក្នុងគ្រួសារ ក៏ដូចជាជីវិតឯកជនផ្ទាល់របស់បងប្អូន ។

ទន្ទឹមនឹងបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ សម្រាប់បងប្អូនជាគ្រីស្តបរិស័ទ នៅពេលនេះ យើងកំពុងតែស្ថិតនៅក្នុងរដូវអប់រំពិសេសដើម្បីឱ្យយើងទាំងអស់ មើលឡើងវិញនូវការប្រព្រឹត្តិរបស់យើងព្រមទាំងការរស់នៅប្រចាំថ្ងៃក្នុងនាមជាគ្រីស្តបរិស័ទ ។

តើយើងបានយកចិត្តទុកដាក់ស្តាប់នូវព្រះបន្ទូល ត្រឹមកម្រិតណា និងប្រណិប័តន៍តាមយ៉ាងណាខ្លះ ? តើយើងចេះទទួលអ្នកដទៃយ៉ាងណា ? តើយើងបានលើកលែងទោសឱ្យគ្នាយ៉ាងដូចម្តេច ? ដើម្បីឱ្យយើងម្នាក់ៗ បានជិតស្និទ្ធជាមួយព្រះជាម្ចាស់ ។

នៅក្នុងរដូវនេះដែរ មានបងប្អូនជាច្រើនដែលត្រៀមខ្លួនទទួលជីវិតថ្មីរួមជាមួយនិងព្រះគ្រីស្ត ។ តើជីវិតថ្មីមានន័យយ៉ាងណាសម្រាប់យើងខ្ញុំម្នាក់ៗ ជាគ្រីស្តបរិស័ទ?

មានតែជំនឿដែលអាចឆ្លើយនឹងសំនួរនេះបាន ហើយមានតែការពឹងផ្អែកទៅលើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលឱ្យយើងទទួលការសង្គ្រោះ និងក៏នាំឱ្យយើងបើកចិត្តដោយទូលំទូលាយ និងក៏គ្មានគំនិតអាត្មានិយមដែលវាជាចំនុចគ្រោះថ្នាក់បំផុតនោះ ។ ជំនឿនាំឱ្យយើងចេះសម្រុះសម្រួលលើកលែងទោសឱ្យគ្នាទៅវិញទៅមក និងជាមាគ៌ានាំយើងឱ្យឆ្ពោះទៅរកសុភមង្គល និងសន្តិ-ភាពក្នុងក្រុមគ្រួសារ និងក្នុងសង្គមជាតិ ។ ការពឹងផ្អែកលើព្រះជាម្ចាស់នាំឱ្យយើងយកពេលជាច្រើនដើម្បីធ្វើការអធិដ្ឋាន ។

តើការដើរតាមព្រះជាម្ចាស់ ធ្វើឱ្យយើងទៅជាមនុស្សកំសាកឬយ៉ាងណា បើយើងមានតែការដាក់ខ្លួនការលើកលែងទោសនោះ ?

**កម្មវិធី ពន្លកថ្មី**
**ជាកម្មវិធីវិទ្យុថ្មីមួយរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក។ កម្មវិធីនេះផ្តោតលើពលកម្មកុមារ និងបញ្ហាការកេងប្រវ័ញ្ចលើកុមារ ដែលសហការជាមួយវិទ្យុសម្លេងប្រជាធិបតេយ្យ VOD មានផ្សាយនៅរាល់ថ្ងៃច័ន្ទ ម៉ោង៤.៥ រសៀល នៅវិទ្យុ FM 106.5 MHz ។**

## កម្មវិធីវិទ្យុ អេម៉ានូអែល

អ្នកចូលរួមកម្មវិធីអេម៉ានូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែមេសា

-ថ្ងៃអាទិត្យទី០៣ ខែមេសា ឆ្នាំ២០១១ អាទិត្យទី៤ ក្នុងរដូវសែសិបថ្ងៃ : លោកបូជាចារ្យបប់ ពិសេ ប្រធានទេវវិទ្យាល័យសន្តយ៉ូហានម៉ារី វីយ៉ាណេ។

-ថ្ងៃអាទិត្យទី១០ ខែមេសា ឆ្នាំ២០១១ អាទិត្យទី៥ ក្នុងរដូវសែសិបថ្ងៃ : លោកបូជាចារ្យផុនផាន ភោគថាវី (លោកពុកចាប់) នៅព្រះសហគមន៍កាតូលិកកំពង់ធំ។

-ថ្ងៃអាទិត្យទី១៧ ខែមេសា ឆ្នាំ២០១១ បុណ្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ : លោកអន់តូនីសាមី ស៊ូសៃរាជ អភិបាលភូមិភាគកំពង់ចាម។

-ថ្ងៃអាទិត្យទី២៤ មេសា ឆ្នាំ២០១១ បុណ្យចម្លងព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង : ចូលរួមដោយលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញសុខកុមារ អូលីវីយេ ស្មីតអ៊ីស្លែរ អភិបាលភូមិភាគភ្នំពេញ។

## កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

ប្រធានបទសម្រាប់ខែមេសា ឆ្នាំ២០១១ (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៤ ខែមេសា : ផឹកខ្លាំង ? ថ្ងៃទី៥ ខែមេសា : ជប់លៀងហើយហាផឹកសុរាឬ ? ថ្ងៃទី១១ ខែមេសា : យុវវ័យ ពីនេះពីនោះក្នុងឱកាសចូលឆ្នាំថ្មី។ ថ្ងៃទី១២ ខែមេសា : យុវវ័យ ពីនេះពីនោះក្នុងឱកាសចូលឆ្នាំថ្មី។ ថ្ងៃទី១៨ ខែមេសា : យុវវ័យ និងអាពាហ៍ពិពាហ៍បង្ខំ។ ថ្ងៃទី១៩ ខែមេសា : យុវវ័យ និងការបោះបង់ចោលការសិក្សា។ ថ្ងៃទី២៥ ខែមេសា : យុវវ័យ និងការដើរលេងយប់។ ថ្ងៃទី២៦ ខែមេសា : យុវវ័យមានការងារធ្វើ មានឯករាជ្យ ? ប្រធានបទទាំងនេះមានវាគ្មិនជំនាញបកស្រាយ។ **សូមកុំភ្លេចតាមដាន!**

# សេដ្ឋកិច្ច

## តម្លៃស្វាយចន្ទីកើនឡើង ខណៈដែលទិន្នផលធ្លាក់ចុះ

**ខាន់ ភីរម្យ**


Photo : L. Sovanna

កសិករមួយចំនួនកំពុងប្រកបរបរធ្វើចំការស្វាយចន្ទីបានអះអាងថា ទិន្នផលស្វាយចន្ទីនៅក្នុងឆ្នាំ ២-០១១នេះ ធ្លាក់ចុះ។ ប៉ុន្តែអ្វីដែលកសិករសប្បាយចិត្តនោះ គឺដំណាំនេះ អាចឡើងថ្លៃ។

លោកអាន ផាវ ម្ចាស់ដំណាំចំការស្វាយចន្ទីមួយកន្លែងនៅស្រុកចំការលើ ខេត្តកំពង់ចាម បានមានប្រសាសន៍ថា ដោយសារតែអាកាសធាតុនៅក្នុងឆ្នាំនេះ មិនអំណោយផល ទិន្នផលដំណាំស្វាយចន្ទីនឹងធ្លាក់ចុះប្រមាណ៥០%។ ប៉ុន្តែយើងសប្បាយបន្តិចដោយសារតម្លៃឡើងថ្លៃ។ លោកបញ្ជាក់ថា: "ឆ្នាំនេះ អត់កក់ខែសោះ។ចន្ទីយើងចេញផ្កាច្រើន។តែអាកាសធាតុក្តៅ ធ្វើឱ្យជ្រុះអស់ប្រមាណ ៥០%។ ប៉ុន្តែសំណាង! តម្លៃឡើងប្រហែលពាក់កណ្តាល"។

តាមការអះអាងរបស់លោកអាន ផាវ ក្នុងផ្ទៃដី ១ហិចតា ដំណាំស្វាយចន្ទីអាចផ្តល់ទិន្នផលជាគ្រាប់ប្រមាណជា ១តោន។ ប៉ុន្តែនៅឆ្នាំនេះ វាប្រហែលបានត្រឹមតែជាងកន្លះតោនប៉ុណ្ណោះ នៅខណៈដែលតម្លៃដំណាំឡើងពី៣៦០០រៀល ទៅ៣៨០០រៀល នៅក្នុង ១គីឡូក្រាម ទៅដល់៦១០០ ដល់៦៥០០ រៀលក្នុងមួយគីឡូក្រាម។

លោកលឹម គឹមហាំង ម្ចាស់ចំការស្វាយចន្ទី ទំហំ ១០០ហិចតា នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ប្រាប់ឱ្យដឹងថា ឆ្នាំនេះគាត់អត់ទាន់លក់ ហើយនៅមិនទាន់ប្រមូលផលអស់ដែរ។ លោកមិនបានផ្តល់តួលេខលំអិតទេ។ តែកាលឆ្នាំមុនគាត់អាចប្រមូលផលបានប្រមាណជា៧០តោន ហើយអាចលក់ចេញក្នុងមួយតោនប្រមាណជា ១០០០ដុល្លារ។

តាមការអះអាងពីម្ចាស់ចំការស្វាយចន្ទីទាំងពីររូបខាងលើនេះ ផលផ្លែស្វាយចន្ទីរបស់ពួកគាត់ភាគច្រើន គឺលក់ទៅឱ្យឈ្មួញវៀតណាមទាំងអស់។

លោកលឹម គឹមហាំង ក៏បានឱ្យដឹងថា ឈ្មួញខ្មែរភាគច្រើន ឱ្យថ្លៃថោកជាងឈ្មួញវៀតណាមហើយមានកម្រិតបរិមាណទិញទៀត។ ប៉ុន្តែឈ្មួញវៀត-ណាម មានប៉ុន្មាន ក៏គេហ៊ានទិញដែរ។

យោងទៅតាមការសិក្សារបស់អង្គការសាជីវ-កម្មហិរញ្ញវត្ថុអន្តរជាតិ ក៏បានឱ្យដឹងថា ដំណាំស្វាយចន្ទី នៅកម្ពុជា អាចមានតម្លៃពី៣០ ទៅ៤០ លានដុល្លារនៅក្នុងមួយឆ្នាំៗ។ ហើយនៅទូទាំងប្រទេសមានអ្នកដែលប្រកបរបរដាំដំណាំនេះមានប្រមាណជា៤០០០គ្រួសារ នាខណៈដែលផលដំណាំនេះអាចដាំបាននៅពាសពេញប្រទេស។

### តួលេខផ្លូវការអះអាងថា កម្ពុជានាំចេញស្វាយចន្ទីបានជាង ៨០០០០ដុល្លារ

ក្រសួងពាណិជ្ជកម្មបានអះអាងថា កាលពីឆ្នាំ ២០១០កន្លងទៅនេះ ប្រទេសកម្ពុជាអាចមានលទ្ធភាពនាំចេញកសិផលស្វាយចន្ទី បានតម្លៃប្រមាណជាង ៨៤,៩១៦ដុល្លារ។

យោងទៅតាមរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្មបានឱ្យដឹងដែរថា នៅក្នុងចំណោមផលិតផលកសិកម្មដែលកម្ពុជាអាចនាំចេញដំណាំស្វាយចន្ទី មានសក្តានុពលនៅទាបជាងផលិតកម្មឈើកែច្នៃ អង្ករ ដំឡូងមី កៅស៊ូ សណ្តែកសៀង និងដំណាំម្រេចទៅទៀត។ ហើយតាមប្រភពដដែលនោះបានឱ្យដឹងថា កម្ពុជាអាចនាំចេញផលិតកៅស៊ូ ៨៧លានដុល្លារ អង្ករបាន ៣៥លានដុល្លារ ឈើ ៣១លានដុល្លារ សណ្តែកសៀង បាន ១១លានដុល្លារ ដំឡូងមីពោត ៨លានដុល្លារ ហើយនិងកសិផលម្រេចបានចំនួន ១២៤.៩៦៥ ដុល្លារផងដែរ។

# សុខភាព

## មុងជ្រលក់ថ្នាំអាចការពារជំងឺគ្រុនចាញ់បានយ៉ាងមានប្រសិទ្ធភាព

**ជាត សំភី**


Photo : S. Philong

លោកវេជ្ជបណ្ឌិត ស៊ីវ សុវណ្ណារដ្ឋ ប្រធានការិ-យាល័យបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ បានប្រាប់ឱ្យដឹងថា មុងជ្រលក់ថ្នាំមានប្រសិទ្ធភាពខ្ពស់ ការពារមូសដែកគោញី ដែលជាភ្នាក់ងារចម្លងជំងឺគ្រុនចាញ់។

លោកវេជ្ជបណ្ឌិតស៊ីវ សុវណ្ណារដ្ឋមានប្រសាសន៍ទៀតថា មុងជ្រលក់ថ្នាំមានពីរប្រភេទ។ ទីមួយគឺប្រភេទមុងធម្មតា ដែលគេទិញថ្នាំយកមកជ្រលក់ ហើយប្រសិទ្ធភាពរបស់វា មាន ៣ឆ្នាំ ឬក៏គេអាចបោកគក់បានចំនួន២០ដង។ មុងប្រភេទទីពីរ គឺមុងដែលជ្រលក់ថ្នាំចេញពីរោងចក្រតែម្តង។ មុងនេះគឺមានក្រឡារឹង និងអាចការពារមូសបានបីឆ្នាំដែរ។

លោកវេជ្ជបណ្ឌិតស៊ីវសុវណ្ណារដ្ឋ បញ្ជាក់ថា មកទល់ពេលនេះ អាជ្ញាធរជាតិប្រយុទ្ធទៅនឹងជំងឺគ្រុនចាញ់ បានរៀបចំកម្មវិធី ចែកមុងដល់ប្រជាជនបាន ៨០% ហើយនៅក្នុងចំណោមមនុស្ស ៣លាននាក់ដែលរស់នៅជិតតំបន់ព្រៃក្នុងបរិវេណ ២គីឡូម៉ែត្រ ដែលងាយឆ្លងជំងឺគ្រុនចាញ់។ ហើយការចែកជូននេះ គឺមិនមានគិតប្រាក់ទេ។

លោកវេជ្ជបណ្ឌិតស៊ីវ សុវណ្ណារដ្ឋ គូសបញ្ជាក់ថា មុងជ្រលក់ថ្នាំ នៅពេលប្រើ បើមានការសាប់ជើងមុងមិនបានត្រឹមត្រូវ រហែកបន្តិចបន្តួច ឬក៏ដាក់ដៃជាប់មុង មូសនៅតែមិនអាចខាំបាន ពីព្រោះពួកវាធុំក្លិនថ្នាំ ឬអាចស្លាប់នៅពេលប៉ះមុង។

លោកវេជ្ជបណ្ឌិតស៊ីវ សុវណ្ណារដ្ឋ បានសំណូមពរប្រជាជនឱ្យស្វែងយល់ដឹងអំពីជំងឺគ្រុនចាញ់ដែលវាបណ្តាលមកពីមូសដែកគោញីខាំ ពុំមែនមកពីចាញ់ទឹកចាញ់ដីឡើយ។ ការប្រើមុងជ្រលក់ថ្នាំអាចការ-ពារមូសដែកគោញីដែលបង្ករជំងឺគ្រុនចាញ់។ម្យ៉ាងប្រជាជនក៏អាចទិញមុងនេះនៅទីផ្សារផងដែរ។



Photo : S. Philong

# មានការងារ មានឯករាជ្យ តែមិនអាចផ្តាច់ទំនាក់ទំនងគ្រួសារ

**ខាន់ ភិរម្យ**

ទស្សនៈថាមានការងារធ្វើ មានឯករាជ្យភាពពីគ្រួសារ គឺវាត្រឹមត្រូវ ។ ប៉ុន្តែវប្បធម៌ និងប្រពៃណីខ្មែរមិនអនុញ្ញាតិឱ្យយុវជនកាត់ផ្តាច់ទំនាក់ទំនងពីគ្រួសារឡើយ ។

លោកសុខន រតនា កំពុងតែបម្រើការនៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន មួយរូប បានអះអាងថា វប្បធម៌ និងប្រពៃណីខ្មែរ មិនតម្រូវឱ្យយុវជនកាត់ផ្តាច់ទំនាក់ទំនងចេញពីគ្រួសារបានឡើយ ។ យុវជន និងគ្រួសារតែងមានទំនាក់ទំនងគ្នាជានិច្ច ។ លោកបានបញ្ជាក់ថា: "ជាការពិត! យើងតែងតែឮពាក្យដំណាល ដែលចាស់ៗ តែងតែនិយាយ ដូចជា "មានការងាធ្វើហើយ ដុះស្លាប" "ចាស់ៗឃើញពន្លឺព្រះអាទិត្យមុន" ឬក៏"ចាស់ៗស្គាល់ទឹកត្រជាក់ទឹកក្តៅមុន"...។ ទាំងនេះគឺជាឃ្លាដែលចាស់ៗនិយាយរិះគន់យុវវ័យតែប៉ុណ្ណោះ ។ ប៉ុន្តែទំនាក់ទំនងរវាងយុវជនយុវនារី ព្រមទាំងគ្រួសារ ខ្ញុំមិនដែលឃើញនរណាម្នាក់អាចកាត់ផ្តាច់ទំនាក់ទំនងនៅឡើយ"។ លោករតនាដែលកំពុងតែបម្រើការងារជាមួយនិងប្រាក់បៀវត្សរ៍ជាមធ្យម ២៥០ដុល្លារ នៅក្នុងមួយខែ បានឱ្យដឹងថា ជាទូទៅកាលណាយើងមានប្រាក់ចំណូលផ្ទាល់ខ្លួន ការសម្រេចចិត្តនៅក្នុងការធ្វើអ្វីមួយ វាងាយស្រួល មិនដូចជា កាលនៅពេល ដែលយើងនៅពឹងពាក់អាណាព្យាបាលនោះឡើយ ។ តែយើងក៏នៅតែមិនអាចឯករាជ្យ ឬកាត់ផ្តាច់ទំនាក់ទំនងពីគ្រួសារទាំងស្រុងបាននោះដែរ ។ លោកបានបញ្ជាក់ថា : "បើមិនមានការងារធ្វើ យើងចង់ប្រើទូរស័ព្ទល្អ យើងត្រូវតែរណបជាមួយគាត់ ។ ប៉ុន្តែបើយើងមានការងារធ្វើ យើងចង់ទិញ តែបើគាត់មិនឱ្យទិញ យើងពន្យល់គាត់ពីហេតុផល"។

កញ្ញាមឿន ស្រីម៉ៅ អាយុ២៥ឆ្នាំ បានឱ្យដឹងដែរថា កាលនៅក្មេងៗកាលណាតែខឹងអាណាព្យាបាល កញ្ញាតែងតែគិតថា កាលណាតែមានការងារធ្វើនឹងឯករាជ្យហើយ ។ ប៉ុន្តែដល់ពេលមានការងារធ្វើ គឺនៅតែដដែល ។ នេះគឺដោយសារតែផ្នត់គំនិត និងការអនុវត្តទៅតាមគន្លងវប្បធម៌ ។ កញ្ញាបានបញ្ជាក់ថា: "កូនខ្មែរមិនដូចកូនអឺរ៉ុបទេ តែមានការងារធ្វើគេអត់នៅផ្ទះទេ ។គេចេញទៅនៅក្រៅហើយ ។ តែកូនខ្មែរដូចខ្ញុំ អត់ទេ ហើយបើចង់ធ្វើអ្វី ក៏ពិគ្រោះយោបល់គ្នាមុនដែរ ទើបសម្រេចចិត្តជាក្រោយ"។ កញ្ញាក៏បានឱ្យដឹងទៀតដែរថា នៅស្រុកខ្មែរទំនាក់ទំនងគ្រួសារមិនដូចជានៅអឺរ៉ុបនោះទេ ។ នៅអឺរ៉ុប ទំនាក់ទំនងគ្រួសាររវាងអាណាព្យាបាល និងកូនៗ ដូចជាមិនសូវជិតស្និទ្ធដូចខ្មែរទេ ដោយសារតែពួកគេ ដូចជាអាចរស់នៅរៀងៗខ្លួន ។ នៅស្រុករបស់គេ អាណាព្យាបាលគេមានរដ្ឋជួយចិញ្ចឹមនិងធ្វើការទំនុកបម្រុង ។ ប៉ុន្តែនៅស្រុកខ្មែរខុសគ្នាដោយសារតែអាណាព្យាបាល មានកាតព្វកិច្ចចិញ្ចឹមបីបាច់កូន ហើយដល់ពេលកូនរបស់ពួកគាត់ធំ មានការងារធ្វើ ក៏ត្រូវមានកាតព្វកិច្ច មើលថែរក្សាអាណាព្យាបាលវិញ ។ ដូច្នេះហើយបានជាទំនាក់ទំនងរវាងអាណា-ព្យាបាល និងកូនមានភាពជិតស្និទ្ធជាង ។

ចំណែកកញ្ញាមិន ស្រីល្បៀប និស្សិតវេជ្ជសាស្ត្រនៅសកលវិទ្យាល័យអាយយូ(IU) បានឱ្យដឹងដែរថា ឥឡូវនេះ កញ្ញាគឺជានិស្សិតទេ ។ ប៉ុន្តែបើសិនជាថ្ងៃមុខ មានការងារធ្វើ ក៏កញ្ញាប្រហែលមិនឯករាជ្យទាំងស្រុងដែរ ។ កញ្ញាបានបញ្ជាក់ថា : "តាមមើលទៅ ប្រសិនខ្ញុំមានការងារធ្វើ ខ្ញុំក៏នឹងអាចសម្រេចចិត្តលើការងារខ្លះ ។ ប៉ុន្តែភាពឯករាជ្យ គឺអាចមានត្រឹមតែ៧០%ទេ ពោលគឺពុំដល់ ១០០%ឡើយ"។ កញ្ញាបានឱ្យដឹងទៀតផងដែរថា បើទោះបីជាយើងមានការងារក៏ដោយ ក៏យើងត្រូវតែទទួលស្គាល់នូវយោបល់ និងគំនិតរបស់អាណាព្យាបាលផងដែរ ។ កញ្ញាមិន ស្រីល្បៀប បានបញ្ជាក់ឱ្យដឹងទៀតដែរថា: "អាណាព្យាបាលជាអ្នកឱ្យកំណើតឱ្យយើង និងជាអ្នកមានគុណរបស់យើង"។

# កសិកម្ម

# ជំងឺសារទឹក អត្រាព្យាបាលជាមានខ្ពស់ បើដឹងទាន់ពេលវេលា


Photo : P. Samphy; RUA

**ជាត សំភី**

បើយោងតាមអ្នកជំនាញជំងឺសារទឹកធ្វើឱ្យសត្វពាហនៈមានគ្រោះថ្នាក់ស្លាប់កម្រិតខ្ពស់ ប្រសិនបើកសិករមិនបានចាប់អារម្មណ៍នឹងរោគសញ្ញារបស់វានោះ និងរកវិធីព្យាបាលឱ្យទាន់ពេលវេលាទេ ។

សារទឹកជាជំងឺកើតលើសត្វពាហនៈជាពិសេសគោក្របី ។ ជំងឺនេះវាបង្កឡើងដោយពពួកបាក់តេរីប៉ាស្ទ័រ៉ាឡា ម៉ុលតូស៊ីដា (Pasteuralla, Multocida) ។ ជំងឺនេះច្រើនរាលដាលនៅរដូវដើមឆ្នាំ ដែលមានភ្លៀងធ្លាក់មួយមេ ឬពីរមេ ដែលវាធ្វើឱ្យមានសំណើមខ្ពស់ និងជាកត្តាជំរុញឱ្យការរីកលូតលាស់យ៉ាងឆាប់រហ័សរបស់បាក់តេរីបង្ករជំងឺ ។

លោកជា ប៊ុនថុន ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម បានមានប្រសាសន៍ឱ្យដឹងថា : "នៅពេលយើងដឹងអំពីរោគសញ្ញាមុន ២៤ម៉ោង លទ្ធភាពនៃការព្យាបាលគឺមានខ្ពស់ គឺរហូតដល់ ៩០% គ្រាន់តែរយៈពេលព្យាបាល គឺយូរ ។ ប៉ុន្តែបើយើងទុកបណ្តោយវា រហូតដល់ថ្ងៃទីពីរ ឬទីបី លទ្ធភាពនៃការព្យាបាល គឺមិនកំណត់ ហើយអត្រាសត្វស្លាប់នេះមានកម្រិតខ្ពស់" ។

លោកជា ប៊ុនថុន បញ្ជាក់ដែរថា រោគសញ្ញានៃជំងឺសារទឹកមានការរឹង និងហើមនៅដើមក ហើយមានលាយឡំនឹងការហៀរសម្បោរ ។ សត្វដង្ហក់ៗខ្លាំង ។ កម្តៅរបស់សត្វអាចកើនឡើងខ្ពស់ដល់៤១អង្សារសេ ។ សត្វបាត់បង់ការស៊ីចំណី និងមានការលំបាកក្នុងការបំផ្លាស់ទី និងសកម្មភាពវាថយចុះ ។ ជួនកាលជំងឺនេះធ្វើឱ្យសត្វស្លាប់លឿនដែរក្នុងរយៈពេល៤៨ម៉ោង ឬ២៤ម៉ោងបើសិនជាសណ្ឋានរបស់វាស្រួចស្រាវខ្លាំង ។ លោកជា ប៊ុនថុន បានផ្តាំផ្ញើថា ប្រសិនបើកសិករឃើញនូវរោគសញ្ញាទាំងនេះ សូមចាប់អារម្មណ៍ និងស្វែងរកសេវាកម្មបសុពេទ្យ នៅតាមមូលដ្ឋាន ដើម្បីធ្វើការព្យាបាលឱ្យវាទាន់ពេល និងកុំឱ្យហួសពេល ។

លោកជា ប៊ុនថុនបញ្ជាក់ទៀតដែរថា ដើម្បីការពារជំងឺសារទឹក គោលការណ៍សំខាន់ទីមួយ គឺការចាក់វ៉ាក់សាំង ។ កសិករ ត្រូវចាក់វ៉ាក់សាំងសារទឹករយៈពេល ៦ខែម្តង ជាពិសេសមុនរដូវភ្លៀងធ្លាក់ ។ បន្ទាប់មកការចិញ្ចឹមសត្វ គឺត្រូវគោរពតាមគោលការណ៍អនាម័យ ។ កសិករត្រូវតែធ្វើសម្អាតក្រោលកន្លែងស៊ីចំណី និងស្វែងរកចំណីដែលមានគុណភាពឱ្យសត្វស៊ី ។ លោកជា ប៊ុនថុន បន្តទៀតថា ប្រការសំខាន់មួយទៀតនោះ គឺកុំព្រលែងសត្វឱ្យដើរពាសវាលពាសកាល ដែលអាចចម្លងជំងឺទៅសត្វផ្សេងៗ ឬឆ្លងមកពីសត្វផ្សេងៗ ដែលនាំឱ្យជំងឺផ្ទុះឡើងនិងរីករាលដាលខ្លាំងឡើងៗ ។

## បរិស្ថាន

# អ្នកជំនាញ : "ចំនួនសត្វដំរីនៅកម្ពុជាអាចនៅដដែល ឬកើនឡើង"

"សត្វដំរីនៅកម្ពុជាជាពូជដំរីអាស៊ី ហើយចំនួនរបស់វាអាចស្ថិតនៅចន្លោះចាប់ពី៤០០ ទៅ៥០០ក្បាល នាពេលសព្វថ្ងៃនេះ" ។ នេះបើតាមប្រសាសន៍របស់អ្នកជំនាញ ។

លោកទុយ សិរីវឌ្ឍនា ជាប្រធានគម្រោងក្រុមអភិរក្សដំរីកម្ពុជានៃអង្គការរុក្ខជាតិ និងសត្វអន្តរជាតិ និងជាម្ចាស់ពានរង្វាន់បុរសមាសផ្នែកបរិស្ថានឆ្នាំ២០១០ នៅអាស៊ី មានប្រសាសន៍ថា ដំរីទាំងនោះភាគច្រើនរស់នៅក្នុងតំបន់ព្រៃការពារ ប៉ែកនិរតីនៃកម្ពុជា នៅតាមជួរភ្នំក្រវាញ់នៅខេត្តកំពតព្រះសីហនុ កោះកុង កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង និងព្រៃប៉ែកឦសានប្រទេស មាននៅមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ ។

លោកទុយ សិរីវឌ្ឍនា បានបន្តថា ចំនួនដំរីអាចមានច្រើនជាងនេះ រហូតដល់៧០០ក្បាល ដោយសារតែមានដានលាមករបស់កូនដំរីតូចៗ ។ លោកក៏បន្ថែមថា កំណើននេះបណ្តាលមកពីការបរបាញ់មានការធ្លាក់ចុះ ។ ហើយព្រៃដែលជាដែនជម្រករបស់វាត្រូវបានការពារយ៉ាងតឹងរ៉ឹងពីរដ្ឋបាលព្រៃឈើ និងការអភិរក្សអង្គការបរិស្ថាននានា ។

លោកទុយ សិរីវឌ្ឍនាសំណូមពរថា រដ្ឋាភិបាល និងប្រជាជនពលរដ្ឋគួរចូលរួមអភិរក្សសត្វដំរី ពីព្រោះវាមានប្រយោជន៍ច្រើនទាំងក្នុងបរិស្ថានជីវចម្រុះ និងបម្រើមនុស្សដូចជាលើកស្ទួយសេដ្ឋកិច្ចជាតិតាមរយៈវិស័យទេសចរណ៍ ។

**ជាត សំភី**


Photo : P. Samphy

# អង្គការព្រះសហគមន៍កាតូលិក

# សមាគមពន្លកថ្មីផ្តល់ទឹកស្អាត និងមានសុវត្ថិភាពដល់ប្រជាជន

**ជាត សំភី**

ប្រជាជនប្រហែល ១៦៨០ គ្រួសារមានលទ្ធភាពទទួលទានទឹកស្អាត ដោយសារតែកម្មវិធី ទឹកស្អាតរបស់សមាគមពន្លកថ្មីនាពេលបច្ចុប្បន្ននេះ ។ ប្រជាជនទាំង ១៦៨០គ្រួសារនោះ រស់នៅក្នុងឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល ។

បងស្រីអាន ម៉ារី ហ្គាលីស ជាអ្នកទទួលខុសត្រូវក្រុមគ្រួសារបុព្វជិតាព្រះមាលា និងជាប្រធានសមាគមពន្លកថ្មី ក៏បានមានប្រសាសន៍ថា នៅតំបន់នោះប្រជាជនមិនអាចជីកអណ្តូងបានទេដោយសារមានជាតិពុលអាសេនិកនៅពីក្រោមដី ។ ដូច្នេះពួកគាត់មានការលំបាកក្នុងការរកទឹកទទួលទាន ។ជួនកាលពួកគាត់ត្រូវទៅដងពីទន្លេដែលនៅឆ្ងាយ ។ បងស្រីបញ្ជាក់ថា : "យើងចង់ផ្តល់ឱ្យគាត់នូវទឹកដែលមានសុវត្ថិភាព ជៀសវាងពួកគាត់ប្រើទឹកកខ្វក់" ។

លោកស៊ិន ទូច អ្នកចាត់ចែងកម្មវិធីពន្លកថ្មីមានប្រសាសន៍ថា យើងហៅកម្មវិធីនេះថា កម្មវិធីទឹកស្អាត ១០០១ ផ្តល់មូលនិធិដោយអង្គការ ១០០១ ពីប្រទេសបារាំង ។ អង្គការនេះគឺមានឯកទេសខាងផលិតទឹកស្អាតសម្រាប់ទទួលទាននៅជុំវិញពិភពលោក ។ លោកស៊ិន ទូចបន្តថា បើតាមតម្លៃទីផ្សារក្រុមហ៊ុនទឹកបរិសុទ្ធនានាលក់ទឹក១ធុង ចំណុះ២០លីត្រ ប្រហែលជា៤០០០រៀល ។ចំណែកយើងលក់តែ ១០០០រៀលប៉ុណ្ណោះ ក្នុងចំណុះដូចគ្នា ។ ដូច្នេះប្រជាជនជាច្រើនមានលទ្ធភាពទិញយកទៅទទួលទានជាពិសេសអ្នកក្រីក្រ ។ លោកបន្តទៀតថា ប្រជាជនប្រហែល៦០០នាក់ ឬ១២០ គ្រួសារមានទឹកបរិសុទ្ធរបស់យើងនៅផ្ទះរបស់ពួកគាត់រួចហើយ ។

ចំណែកក្រៅពីនេះ យើងផ្តល់ទឹកបរិសុទ្ធដោយមិនគិតថ្លៃដល់សាលារៀន និងវត្តនៅក្នុងឃុំសារិកាកែវផងដែរ ។ លោកស៊ិន ទូចបន្ត ឱ្យដឹងទៀតថា: "កម្មវិធីនេះមានគោលបំណងជួយដល់ប្រជាជនជាពិសេសអ្នកក្រីក្រ ឱ្យអាចទទួលទានទឹក ដែលមានអនាម័យ ។ បើធ្វើដូច្នេះពួកគាត់អាចមានជីវភាពល្អប្រសើរបានដោយសារតែពួកគាត់គ្មានឆ្លងជំងឺដែលត្រូវចំណាយថ្នាំព្យាបាល មិនមានចំណាយថ្លៃអុស ឬអាចយកពេលវេលាដាំទឹកទៅធ្វើអ្វីផ្សេងទៀតដែលជាប្រយោជន៍ដល់គ្រួសារ" ។ លោក ស៊ិន ទូច បន្ថែមថា : "អាជ្ញាធរបានសហការល្អជាមួយយើងដោយផ្តល់កន្លែងសម្រាប់ផលិតកម្ម" ។



Photos : P. Samphy

កូនសិស្សនៅសាលាបឋមសិក្សាសារិកាកែវ ឃុំសារិកាកែវ ស្រុកល្វាឯម មានទឹកស្អាតបរិភោគនៅក្នុងថ្នាក់រៀន

លោកប៊ូ ទីឡាត អ្នកផលិតទឹកស្អាត បានមានប្រសាសន៍ថា គុណភាពរបស់ទឹកយើងនេះត្រូវបានទទួលស្គាល់ដោយអ្នកឯកទេសពីប្រទេសបារាំងថាមានភាពល្អប្រសើរក្នុងកម្រិត៩៩.៩% ។ ដូច្នេះទឹកស្អាតមិនប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ទេ មានតែជួយសុខភាព ។ កន្លងមក យើងក៏មានការលំបាកខ្លះ ក្នុងការបំពេញតម្រូវការរបស់អតិថិជនដែលចេះតែកើនឡើង ។ តែយើងបំពេញបាន ។

លោកម៉ន តៅ អ្នកភូមិក្តីកណ្តាល ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល មានប្រសាសន៍ថា លោកបានទិញទឹកសុទ្ធរបស់សមាគមដោយសារលក្ខខណ្ឌវាល្អ ។ មានអនាម័យ ។ មានតម្លៃថោកទោះបីអ្នកក្រីក្រក៏អាចទិញបាន ។ លោកក៏បន្តថា: "កាលមុនខ្ញុំចំណាយលុយកាក់ និងពេលវេលាដើម្បីទិញអុសយកមកដាំទឹកហូប ។ តែឥឡូវដោយសារទឹកសុទ្ធនេះ ខ្ញុំមានពេលទំនេរច្រើនជាង ដើម្បីធ្វើអ្វីផ្សេងៗ ដើម្បីចិញ្ចឹមជីវភាព" ។

លោកសន គ្រេង អ្នកភូមិម្នាក់ទៀត បានមានប្រសាសន៍ដែរថា ជាមួយនិងដបទឹកសុទ្ធនេះលោកមានអារម្មណ៍សប្បាយចិត្ត គឺដោយសារលោកអាចកាត់បន្ថយការចំណាយ ។ លោកបញ្ជាក់ថា: "តាំងពីប្រើទឹកសុទ្ធនេះ យើងមិនមានជម្ងឺរាគរូសអ្វីទេ" ។



ចំណែកលោកប៊ូ សុផល ជានាយកសាលាបឋមសិក្សាសារិកាកែវ បានមានប្រសាសន៍ឱ្យដឹងដែរថា សមាគមពន្លកថ្មី ផ្តល់ឱ្យយើងនូវទឹកសុទ្ធ ១៥ធុង សម្រាប់ ១៥ថ្នាក់ជារៀងរាល់ថ្ងៃ ។ ទឹកជួយសិស្សបានច្រើន ។ កន្លងមកកូនសិស្សខ្លះមកសាលាដោយគ្មានលុយទេ ។ ពួកគេមិនអាចរកទិញទឹកស្អាតផឹកបានឡើយ ។ ដូច្នេះពួកគេតែងតែស្រេកទឹក តែពួកគេទ្រាំដែលធ្វើឱ្យពិបាករៀនសូត្រ ។ លោកបន្តថា : "ឥឡូវនេះសិស្សរបស់យើងមានទឹកបរិភោគ ។ ពួកគេមានការប្រមូលផ្តុំអារម្មណ៍បានល្អ ហើយដោយសារតែទឹកនេះ" ។លោកបញ្ជាក់ផងដែរថា: "ខ្ញុំចង់ថ្លែងអំណរគុណដល់កម្មវិធីរបស់អង្គការ" ។

សមាគមពន្លកថ្មី ត្រូវបង្កើតឡើងដោយបងស្រីអាន ម៉ារី ហ្គាលីស នៅថ្ងៃទី២ កុម្ភៈ ឆ្នាំ ២០០៣ ។ ក្រៅពីកម្មវិធីផលិតទឹកបរិសុទ្ធនេះ សមាគមពន្លកថ្មី មានធ្វើជាកម្មវិធីទឹកស្អាតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលផងដែរ តាមរយៈរូបភាពផ្សេងពីនេះ គឺការចូលរួមជីកអណ្តូង ឱ្យប្រជាជន មានទឹកស្អាតសម្រាប់ប្រើប្រាស់ ។

ក្រៅពីកម្មវិធីនេះ សមាគមពន្លកថ្មី ក៏បានជួយប្រជាជនជនបទដូចជា ការពិនិត្យសុខភាពដល់អ្នកក្រីក្រ ដោយមិនគិតថ្លៃ ផ្តល់ការគាំទ្រលុយកាក់កុំឱ្យសិស្សបោះបង់ចោលសាលា កម្មវិធីបណ្ណាល័យ និងសាលាមត្តេយ្យ និងកម្មវិធីជាច្រើនទៀត ។



Photo : S. Philong

**ខាន់ ភីរម្យ**

## ធនាគារពិភពលោក : "កម្ពុជាទទួលកំណើនសេដ្ឋកិច្ច ៦,៥%"

ធនាគារពិភពលោកបានអះអាងថា ឆ្នាំនេះកម្ពុជានឹងមានកំណើនសេដ្ឋកិច្ច ៦,៥% ។

លោកជា ហូត អ្នកសេដ្ឋកិច្ចរបស់ធនាគារពិភពលោកប្រចាំកម្ពុជា បានអះអាង ក្នុងសន្និសីទសារព័ត៌មានមួយកាលពីខែមីនាថា កំណើននេះគឺដោយសារតែការនាំចេញរបស់កម្ពុជា នៅតែមានលក្ខណៈល្អ កំណើនវិនិយោគទុនដោយផ្ទាល់ពីបរទេស និងកំណើនកសិកម្ម និងទេសចរណ៍ជាដើម ។

បើតាមរបាយការណ៍របស់ធនាគារពិភពលោក ការនាំចេញរបស់កម្ពុជានឹងនៅល្អប្រសើរដោយផ្អែកនៅលើលក្ខណៈអនុគ្រោះរបស់សហភាពអឺរ៉ុប ។ វិនិយោគផ្ទាល់ពីបរទេសនឹងកើនដល់ ៥,៤% នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០១០ និងដល់ ៦% ក្នុងឆ្នាំ២០១១ ។ ចំណែកកសិកម្មកើនឡើង ៥,៣% ក្នុងឆ្នាំ២០១០ ការនាំចេញសម្លៀកបំពាក់បានកើនឡើង ២៤% ក្នុងឆ្នាំ២០១០ ។

ការព្យាករណ៍នេះគឺទាបជាងការព្យាករណ៍របស់រដ្ឋាភិបាល 0.៥% ។

## ពលករកម្ពុជាទៅធ្វើការ ក្រៅប្រទេសជាង ១២៦.000នាក់

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអះអាងថា កាលពីឆ្នាំ២០១០កន្លងទៅនេះ កម្ពុជាបានបញ្ជូនពលករ និងពលការិនីប្រមាណជាង ១២៦000នាក់ ទៅធ្វើការនៅក្រៅប្រទេស ជាមួយនិងប្រាក់ចំណូលផ្ញើមកក្នុងស្រុក ប្រមាណជា ១៨0 លានដុល្លារក្នុងមួយឆ្នាំៗ ។

យោងទៅតាមរបាយការណ៍របស់ក្រសួងបានឱ្យដឹងថា តាមរយៈក្រុម-ហ៊ុន ចំនួន៣៣ ដែលទទួលអាជ្ញាបណ្ណកម្ពុជាបានបញ្ជូនពលករ និងពលការិនីចំនួន១៦៣៩៤នាក់ ទៅប្រទេសម៉ាឡេស៊ី ចំនួន ១១២២៤នាក់ ទៅថៃ ហើយ ២១១៦នាក់ ទៅកូរ៉េខាងត្បូង ក្រៅពីនោះនៅមានទៅជប៉ុនផងដែរ ។

ប្រភពដដែលបានឱ្យដឹងថា ពួកគេទទួលប្រាក់បៀវត្សរ៍ប្រមាណជាពី ២00 ដុល្លារទៅជាង ១000ដុល្លារ ។

## អ្នកវិនិយោគទុនជប៉ុន ៤៩ ក្រុមហ៊ុនមកស្វែងរកឱកាសវិនិយោគនៅកម្ពុជា

អ្នកវិនិយោគទុនជប៉ុនប្រមាណ ៤៩ក្រុមហ៊ុន បានមកស្វែងរកឱកាសវិនិយោគនៅក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី២១ ខែមីនា កន្លងទៅនេះ បើទោះបីជាជប៉ុនកំពុងតែរងគ្រោះដោយសារតែស៊ូណាមិ និងការរញ្ជួយដីយ៉ាងធ្ងន់ធ្ងរក៏ដោយ ។

លោកស៊ូសាគូ ណាកាមូរ៉ា ប្រធានវិទ្យាស្ថានវិនិយោគទុនអន្តរជាតិជប៉ុន បានឱ្យដឹងថា អ្នកវិនិយោគទុនទាំងអស់ មានចំនួន ៨៥នាក់ តំណាងឱ្យក្រុមហ៊ុនចំនួន ៤៩ បានមកដល់ប្រទេសកម្ពុជាដើម្បីសិក្សាទៅលើឧស្សាហកម្ម ភោជនីយដ្ឋាន សំណង់ និងវិស័យទេសចរណ៍ ។

ឯកឧត្តមចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអះអាងថា ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចបើកទូលាយ ពិសេស គឺកម្ពុជាមានកិច្ចព្រមព្រៀងការពារវិនិយោគទុនជប៉ុន និងទទួលបានការលើកលែងពន្ធជាច្រើនក្នុងការនាំចេញទំនិញទៅកាន់ប្រទេសជប៉ុនផងដែរ ។

# សហគមន៍អន្តរជាតិបើកការវាយប្រហារទៅលើប្រទេសលីប៊ី

ក្នុងកិច្ចប្រឹងប្រែងដើម្បីការពារជនស៊ីវិល សហគមន៍អន្តរជាតិ មានអាមេរិក អង់គ្លេសនិងបារាំង បានបើកការវាយប្រហារតាមផ្លូវអាកាសប្រឆាំងទៅលើកងទ័ពដែលស្មោះស្ម័គ្រនឹងមេដឹកនាំប្រទេសលីប៊ី ។

ប្រតិបត្តិការនេះ គឺបានធ្វើឡើង ក្រោយពេលដែលរបបដឹកនាំរបស់លោកមូអាមម៉ា អាល់ ហ្គាដាហ្វី បានបើកការវាយប្រហារទៅលើក្រុមមនុស្ស ដែលងើបឡើងប្រឆាំងនឹងការគ្រប់គ្រងដ៏យូររបស់លោក ។

ប្រតិបត្តិការនេះបានចាប់ផ្តើមកាលពីថ្ងៃទី១៩ ខែមីនា ហើយមកដល់ចុងខែ កងកម្លាំងសម្ព័ន្ធមិត្ត ដែលបានប្រគល់ភារៈឱ្យអង្គការណាតូបានកាន់កាប់ដែនអាកាសរបស់ប្រទេសនេះ ហើយប្រកាសថាជាតំបន់គ្មានការហោះហើរដើម្បីការពារជនស៊ីវិលប្រឆាំងនឹងការបង្ក្រាបរបស់ក្រុមទាហានរបស់លោកហ្គាដាហ្វី ។

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបើកភ្លើងខៀវសម្រាប់ការវាយប្រហារនេះជាមួយនិងសម្លេងគាំទ្រពីប្រទេសសមា-ជិកក្រុមប្រឹក្សា សន្តិសុខ ៣ប្រទេស គឺអាមេរិក បារាំង និងអង់គ្លេស ។ ចំណែកប្រទេសរុស្ស៊ី និងចិន បោះឆ្នោតអនុប្បវាទ ។

### ជប៉ុនរងគ្រោះធ្ងន់ព្រោះការរញ្ជួយដី និងស៊ូណាមិ

ចំនួនមនុស្សលើសពី ១0.000នាក់ ត្រូវបានអះអាងថា បានបាត់បង់ជីវិត ហើយមនុស្សប្រមាណ១៧៥00នាក់ទៀត បានបាត់ខ្លួន ហើយនិងមានការប្រឈមមុខនឹងការលេចធ្លាយវិទ្យុសកម្ម-ចេញពីរោងចក្រថាមពលអគ្គិសនីដែលដើរដោយថាមពលនុយ-ក្លេអ៊ែរ ដែលប៉ះពាល់ដោយស៊ូណាមិ និងការរញ្ជួយដីក្នុងកម្លាំងរហូតដល់ ៩រ៉ិចទ័រ ។

គ្រោះរញ្ជួយដីនេះបានកើតមានឡើងកាលពីថ្ងៃទី១១ខែមីនា ហើយមកដល់ចុងខែចំនួនជនរងគ្រោះដែលបានបាត់បង់ជីវិតនៅបន្តកើនឡើង ហើយគ្រោះមហន្តរាយនៅពុំទាន់បានដោះស្រាយនៅឡើយ ជាពិសេស ការលេចធ្លាយជាតិវិទ្យុសកម្មចេញពីរោងចក្រដើរដោយថាមពលនុយក្លេអ៊ែរ ហ្វូគូស៊ីម៉ា ហើយមានសេចក្តីរាយការណ៍ថា វិទ្យុសកម្មបានធ្លាយចូលក្នុងប្រភពទឹក ។

ប្រទេសមួយចំនួនបានធ្វើការហាមឃាត់នាំចូលទំនិញពិសេសបន្លែ និងអាហារពីក្នុងតំបន់នោះ ដោយសារការភ័យខ្លាចវិទ្យុ-សកម្ម នាខណៈដែលកម្មករ និងអ្នកជំនាញការជប៉ុនកំពុងតែតស៊ូទប់ទល់នឹងការធ្លាយចេញជាតិវិទ្យុសកម្មនេះបន្តទៀត ។



Photo : DR

**ខាន់ ភីរម្យ**

# ឯកអគ្គរាជទូត: "ព្រះសហគមន៍កម្ពុជាតូច តែជំនឿមាំ"

**ខាន់ ភីរម្យ**

*លោកជីអូវ៉ាន់នី ដាយ៉េឡូ ឯកអគ្គរាជទូតបុរីវ៉ាទីកង់ ប្រចាំប្រទេសកម្ពុជាដែលមាននិវេសនដ្ឋាននៅក្នុងទីក្រុងបាងកកប្រទេសថៃ បានមកធ្វើបំពេញទស្សនកិច្ចនៅកម្ពុជាជាលើកទី២ រយៈពេល ៤ថ្ងៃ ពីថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែមីនា។ នៅលេខនេះ អ្នកនាំសារសូមណែនាំមិត្តអ្នកអានឱ្យបានជួបផ្ទាល់ តាមរយៈកិច្ចសម្ភាសន៍ជាមួយនិងចំណាប់អារម្មណ៍របស់លោកឯកអគ្គរាជទូតផ្ទាល់។*



លោកអគ្គរាជទូតជីអូវ៉ាន់នី ដាយ៉េឡូ ក្នុងដំណើរទស្សនកិច្ចជាលើកទី២ នៅព្រះរាជាណាចក្រកម្ពុជា

**អ្នកនាំសារ : នេះជាដំណើរទស្សនកិច្ចនៅកម្ពុជារបស់លោកចាប់តាំងពីលោកបានត្រូវតែងតាំងជាឯកអគ្គរាជទូតបុរីវ៉ាទីកង់ប្រចាំប្រទេសកម្ពុជា។ តើអ្វីទៅជាគោលបំណងសំខាន់របស់លោកនៅក្នុងដំណើរទស្សនកិច្ចនៅកម្ពុជាជាលើកទី២ នេះ ?**

**លោកជីអូវ៉ាន់នី ដាយ៉េឡូ:** ក្នុងដំណើរទស្សនកិច្ចជាលើកទី២ របស់ខ្ញុំ លើកនេះគោលបំណងសំខាន់ គឺស្វែងយល់អំពីកិច្ចការ និងសកម្មភាពជួបផ្ទាល់ជាមួយនិងព្រះសហគមន៍កាតូលិក នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងដំណើរទស្សនកិច្ចលើកនេះ ខ្ញុំបានជួបជាមួយនិងលោកបូជាចារ្យ និងគ្រីស្តបរិស័ទ និងក៏បានទៅបំពេញទស្សនកិច្ចនៅមណ្ឌលសកម្មភាពមួយចំនួននៅក្នុងប្រទេសកម្ពុជា ដើម្បីឱ្យយល់អំពីសកម្មភាព និងបេសកកម្មរបស់ព្រះសហគមន៍ ដូចជាផ្នែកសង្គមកិច្ច និងអប់រំជាដើម ។

**អ្នកនាំសារ : តើលោកយល់យ៉ាងណាដែរចំពោះព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជា នៅក្នុងដំណើរទស្សនកិច្ចជាលើកទី២នេះ ?**

**លោកជីអូវ៉ាន់នី ដាយ៉េឡូ :** ខ្ញុំមានចំណាប់អារម្មណ៍ដ៏ខ្លាំងនឹងព្រះសហគមន៍នៅកម្ពុជាតាំងតែពីដំណើរទស្សនកិច្ចនៅកម្ពុជាតាំងពីលើកទីមួយ មកម្ល៉េះ ។ ព្រះសហគមន៍នៅកម្ពុជាគឺជាព្រះសហគមន៍មួយតូច ។ ប៉ុន្តែវាមានការងារជាច្រើនដែលខ្ញុំមានចំណាប់អារម្មណ៍ ពិសេស ទៅលើការអនុវត្តជំនឿ និងកិច្ចការផ្នែកសង្គមជាច្រើន ដែលព្រះសហគមន៍បានធ្វើ ។ នៅក្នុងដំណើរបំពេញទស្សនកិច្ចនេះ ខ្ញុំក៏បានមើលឃើញថា ការងាររបស់ព្រះសហគមន៍នៅកម្ពុជាតែងតែនៅជាប់នឹងប្រជាជន ជាពិសេសប្រជាជនដែលងាយរងគ្រោះ និងកំពុងតែត្រូវការការសង្គ្រោះ ហើយខ្ញុំក៏បានមើលឃើញអំពីជំនឿដ៏មុតមាំរបស់គ្រីស្តបរិស័ទនៅក្នុងប្រទេស ។

**អ្នកនាំសារ : ជាចុងក្រោយតើលោកឯកអគ្គរាជទូតមានសារណាមួយទៅកាន់គ្រីស្តបរិស័ទនៅក្នុងប្រទេសកម្ពុជា ?**

**លោកជីអូវ៉ាន់នី ដាយ៉េឡូ :** ខ្ញុំសូមគាំទ្រកិច្ចការ និងបេសកកម្មដែលព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជាកំពុងតែអនុវត្ត ហើយក៏លើកទឹកចិត្តពួកគេ ជាពិសេសគឺយុវជនឱ្យបន្តអនុវត្តនិងកែលំអនូវការប្តេជ្ញាចិត្តនៅក្នុងការផ្សព្វផ្សាយនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងរាល់សកម្មភាពរបស់ព្រះសហគមន៍កាតូលិកដើម្បីបន្តសក្ខីភាពនៃសេចក្តីស្រលាញ់ សន្តិភាព ការផ្សះផ្សារ និងផ្សព្វផ្សាយនូវដំណឹងល្អ ដើម្បីជួយពង្រឹងជំនឿនិងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការនូវកិច្ចសហប្រតិបត្តិការនៅក្នុងសង្គម ។ ខ្ញុំសូមលើកទឹកចិត្តឱ្យយុវជន ដែលជាអ្នកជំនាន់ក្រោយ ហើយកំពុងតែបំពេញការងារយ៉ាងសកម្មដើម្បីបន្តនូវការខិតខំប្រឹងប្រែងតទៅទៀត ដើម្បីជាសក្ខីភាពនៃតម្លៃរបស់មនុស្ស ។



Photos : V. Sambath

លោកអគ្គរាជទូតជីអូវ៉ាន់នី ដាយ៉េឡូ បានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជាជាលើកទី២ និងបានចូលរួមធ្វើពិធីថ្វាយអភិបូជាជាមួយលោកអភិបាលនៃភូមិភាគកាតូលិកទាំងបីនៅព្រះសហគមន៍ផ្សារតូច រាជធានីភ្នំពេញ។

## ជីវប្រវត្តិរូបសង្ខេបរបស់លោកឯកអគ្គរាជទូត

លោកជីអូវ៉ាន់នី ដាយ៉េឡូ បានត្រូវសម្តេចប៉ាបបេណេឌីកទី១៦ តែងតាំងជាឯកអគ្គរាជទូតបុរីវ៉ាទីកង់ប្រចាំបួនប្រទេសនៅអាស៊ី អាគ្នេយ៍ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០។

លោកប្រសូតនៅថ្ងៃទី៩ ខែមករា ឆ្នាំ ១៩៥៥ នៅក្នុងប្រទេសអ៊ីតាលី។ លោកបានចូលបម្រើការងារនៅក្នុងវិស័យការទូតរបស់បុរីវ៉ាទីកង់ចាប់តាំងពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ១៩៨៣ ក្រោយពេលដែលលោកបានចូលសិក្សាវិទ្យាសាស្ត្រការទូតនៅរ៉ូម។ មុនពេលតែងតាំងជាឯកអគ្គរាជទូតនៅកម្ពុជា ថៃ ឡាវ និង ភូមា លោកជីអូវ៉ាន់នី ដាយ៉េឡូ ជាឯកអគ្គរាជទូតរបស់បុរីវ៉ាទីកង់ ប្រចាំនៅប្រទេសកុងហ្គោ។

# បទយកការណ៍

# កម្ពុជាជាប្រទេសកសិកម្ម ប៉ុន្តែឥណទានផ្តោតសម្រ

**ខាន់ ភីរម្យ**



កសិកម្មនៅកម្ពុជា ជាសសរស្តម្ភមួយនៃសេដ្ឋកិច្ចជាតិ ហើយក៏ជាវិស័យមួយដែលរាជរដ្ឋាភិបាលកំពុងតែជំរុញយកចិត្តទុកដាក់។ ប៉ុន្តែប្រជាពលរដ្ឋនៅឯមូលដ្ឋានមួយចំនួនបានអះអាងថា ឥណទានសម្រាប់វិស័យកសិកម្មគឺនៅមានកម្រិត។

អ្នកមីងវ័ត្ន យ៉ានជាកសិកររស់នៅឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ បានអះអាងថា សព្វថ្ងៃនេះបើយើងទៅខ្ចីលុយអង្គការ (ស្ថាប័នមីក្រូហិរញ្ញវត្ថុ) ហើយប្រាប់គេថា យកទៅធ្វើស្រែគេមិនឱ្យទេ គេថា ខ្លាចអត់អីសង។ ប៉ុន្តែបើយើងប្រាក់គេថា យកទៅចិញ្ចឹមសត្វ ឬទៅធ្វើរបរលក់ដូរគេឱ្យ។អ្នកមីងបានបញ្ជាក់ថា: "ឆ្នាំទៅមិញ ខ្ញុំទៅខ្ចីលុយលោកគ្រូម្នាក់ ចំនួន ២០ម៉ឺនរៀល ហើយថា យកទៅទិញជីនិងជួលគេបូមទឹកដាក់ស្រែ។ គាត់ថា អត់ឱ្យទេ។ ដល់ខ្ញុំទាល់ពេកទៅ ខ្ញុំក៏ទៅខ្ចីពីលោកគ្រូម្នាក់ទៀត ហើយថា យកទៅទិញរបស់(ឥវ៉ាន់) ទុកលក់ពេលបុណ្យគាត់ក៏ឱ្យ"។

លោកជ័យ ជា កសិករនៅភូមិស្រែននោង ស្រុកត្រាំកក់ ខេត្តតាកែវ ដដែល បានឱ្យដឹងថា កាលពីវស្សាមុននេះ វារាំងពេក។ ពូជស្រូវដែលគាត់បានសាប សម្រាប់យកសន្ទូងទៅស្ទូង ងាប់អស់ ហើយដល់ពេលមានភ្លៀងធ្លាក់មក គាត់បានទៅខ្ចីលុយពីអង្គការ ដូចដែលភូមិឯទៀតគេខ្ចីហូរហែ។តែដល់ពេលទៅខ្ចី គេក៏ប្រាប់គាត់ថា អត់ទាន់មានគោលការណ៍គេអត់ហ៊ានឱ្យ។ ដោយសារតែតម្រូវការចាំបាច់ គាត់ក៏ទៅខ្ចីពីអ្នកចងការប្រាក់នៅក្នុងភូមិ។

ជុំវិញបញ្ហានេះ ភ្នាក់ងារឥណទានមួយរូប ដែលសុំមិនបញ្ចេញអត្តសញ្ញាណ បានឱ្យដឹងថា ជាគោលការណ៍ ឥណទានកសិកម្ម នៅក្នុងភូមិសាស្ត្រស្រុកត្រាំកក់ មិនត្រូវបានគាំទ្រឱ្យប្រតិបត្តិការទូទៅទេ ដោយសារតែហានិភ័យមានរាងខ្ពស់ ព្រោះតែផ្ទៃដីរបស់គ្រួសារនីមួយៗ ដែលមានភាគច្រើនគឺតូចៗ។ ប៉ុន្តែបើអាជីវកម្មខ្នាតតូច ដូចជាលក់ដូរ ជំនួញ គឺភាគច្រើនងាយស្រួល។ លោកបានបញ្ជាក់ដែរថា: "អ្នកភូមិខ្លះមានដីតែ ៤ទៅ៥អាអីទេ នៅក្នុងមួយគ្រួសារ។ បើគាត់មកខ្ចីថាទៅធ្វើស្រែ អត់យកទៅធ្វើមុខរបរអីផ្សេង គឺយើងអត់ឱ្យតែម្តងដោយសារតែយើងបារម្ភអំពីលទ្ធភាពសងត្រឡប់"។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានប្រតិបត្តិការគ្របដណ្តប់ ១៤១៥០ភូមិ នៅទូទាំងប្រទេស

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានអះអាងថា មកដល់បច្ចុប្បន្ននេះ សមាគមមានសមាជិកចំនួន ២១ស្ថាប័ន ក្នុងចំណោមស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ចំនួន ២៤ស្ថាប័ន ដែលកំពុងតែប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

តាមប្រភពដដែលនេះ នៅក្នុងចំណោមស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់នោះ មានស្ថាប័នខ្លះមានប្រតិបត្តិករគ្របដណ្តប់ទៅដល់ភូមិចំនួន ១៤១៥០ភូមិ នៅក្នុងឃុំ ២០៦៤ឃុំ ក្នុង ៥៧ស្រុក និង ២៤ខេត្ត-ក្រុង និងរាជធានី។ ស្ថាប័នទាំង ២១នេះ កំពុងតែប្រតិបត្តិការផ្តល់មីក្រូឥណទានទៅដល់ប្រជាពលរដ្ឋប្រមាណជា ១ ២១៧ ២៤៣នាក់ ជាមួយនឹងឥណទានដែលមានតម្លៃប្រមាណជា ៣៩២ លានដុល្លារ។ ហើយនៅក្នុងចំណោមបណ្តាស្ថាប័នទាំងអស់នោះ ក៏មានស្ថាប័នមួយចំនួនបានទទួលអាជ្ញាបណ្ណឱ្យទទួលប្រាក់បញ្ញើពីធនាគារជាតិផងដែរ។

មន្ត្រីឥណទានដដែលនោះបានឱ្យដឹងថា បើទោះបីជាកម្ចីយកទៅធ្វើស្រែ ពុំត្រូវបានលើកទឹកចិត្ត។ ប៉ុន្តែបើសិនអ្នកភូមិមកខ្ចីប្រាក់ទៅបង្កើតមុខរបរនេះ របរនោះ ដូចជាចិញ្ចឹមសត្វ គឺយើងស្វាគមន៍។ លោកបានបន្តទៀតថា នៅក្នុងករណីដែលគាត់មកខ្ចីក្នុងគោលបំណងយកទៅដាំជាដំណាំ ឬបន្លែដែលមានផែនការច្បាស់លាស់យើងក៏ស្វាគមន៍ដែរ។

ដោយសារតែមូលហេតុ និងកត្តាទាំងនេះហើយ ប្រជាពលរដ្ឋមួយចំនួនបានដូរចេញពីការប្រើប្រាស់ប្រព័ន្ធឥណទានផ្លូវការទៅប្រើប្រាស់សេវាឥណទានក្រៅប្រព័ន្ធ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋក្រីក្រគឺរឹតតែប្រឈមមុខខ្ពស់ថែមមួយកម្រិតទៀត បើទោះបីជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ត្រូវបានអះអាងថា កំពុងតែរីកចម្រើនយ៉ាងណាក៏ដោយ។

# ម្រាប់ផ្នែកនេះនៅមានកម្រិត



Photo : S. Philong

លោកជ័យ ជា បានឱ្យដឹងថា កាលដែលគាត់ខកខានមិនបានទទួលឥណទាន ពីស្ថាប័នមីក្រូហិរញ្ញវត្ថុក៏បានធ្វើឱ្យគាត់ត្រូវប្រឈមមុខនឹងការបង់ការប្រាក់ប្រមាណជា៧% នៃទំហំទឹកប្រាក់ ២០០០០០ រៀល ។ ហើយមកទល់សព្វថ្ងៃនេះគាត់នៅមិនទាន់មានលទ្ធភាពសងគេបានគ្រប់នៅឡើយទេ ក្រៅពីបង់ចុងការ ឱ្យគេមួយខែ ១៥០០០រៀល ហើយខែខ្លះក៏ជំពាក់គេ ។ លោកបានឱ្យដឹងថា គាត់ប្រហែលជានឹងលក់គោមួយក្បាលដើម្បីនឹងសងគេ ។ លោកបានបញ្ជាក់ថា: "បើទាល់ខ្លាំងពេកមានតែលក់គោសងគេតែប៉ុណ្ណឹង" ។

ជុំវិញបញ្ហានៃកម្មវិធីឥណទានដែលបានលើកឡើងដោយប្រជាពលរដ្ឋ លោកជាផល្លារិន ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាបានឱ្យដឹងថា គោលដៅសំខាន់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺកែលំអជីវភាពប្រជាពលរដ្ឋក្រីក្រ ។ ហើយវិស័យកសិកម្មក៏ជាគោលដៅសំខាន់មួយផងដែរ ។ តែមុននឹងផ្តល់ឥណទានបាន គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់គាត់ត្រូវតែធ្វើការសិក្សា ពិគ្រោះ និងពិនិត្យ ស្ថានភាពជាក់ស្តែង របស់អតិថិជនរបស់គេផងដែរ ។ លោកបានបញ្ជាក់ថា: "មានប្រជាពលរដ្ឋប្រមាណ ១,២ លាននាក់ក្នុងទំហំឥណទានសរុប ៣៩២លានដុល្លារ និងត្រូវជា ៦០% គឺផ្តោតទៅលើកសិកម្ម ។ តែមុននឹងផ្តល់ឱ្យអតិថិជនណាម្នាក់ ក៏គ្រឹះស្ថានទាំងអស់ត្រូវតែពិនិត្យ និងសិក្សាអំពីអតិថិជនផងដែរដើម្បីធានានិរន្តរភាពស្ថាប័ននីមួយៗ" ។

តាមប្រសាសន៍របស់លោកជា ផល្លារិន សព្វថ្ងៃកម្មវិធីឥណទានរបស់បណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុគឺមានចាប់ពី ១០ដុល្លារ រហូតដល់ ២០០០០ដុល្លារ ឬអាចច្រើនជាងនេះ ទៅតាមទំហំមុខរបរផែនការ និងសមត្ថភាពចាត់ចែងមុខរបរនៃអតិថិជនម្នាក់ៗ នៅក្នុងអត្រាការប្រាក់ពី១,៥% ទៅដល់ ៣% ក្នុងមួយខែ ។ មូលហេតុដែលបណ្តាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់តម្រូវឱ្យធ្វើទៅតាមទម្រង់ការបែបនេះ គឺដើម្បីបង្ការហានិភ័យរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុផ្ទាល់ និងអតិថិជន ជាពិសេសលើសមត្ថភាពសងត្រឡប់មកវិញ ។ លោកជា ផល្លារិនបានឱ្យដឹងថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជារីកចម្រើននិងមានការិយាល័យប្រតិបត្តិការនៅគ្រប់ខេត្ត ហើយមានគ្រឹះស្ថានខ្លះបានបើកការិយាល័យប្រតិបត្តិការរហូតដល់តាមស្រុកផងក៏មាន ។ ប៉ុន្តែទោះជាយ៉ាងណា ក៏បណ្តាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជានៅមិនទាន់អាចមានសមត្ថភាពបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ បានពេញទំហឹងនៅឡើយដែរ ។

លោកប៊ុន មុនី ប្រធានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត បានមានប្រសាសន៍ថាគោលដៅរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ គឺកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ទុនដើម្បីបង្កើតមុខរបរ និងការងារដល់ប្រជាជន ។ ប៉ុន្តែនិរន្តរភាពក៏ត្រូវតែគិត ។

លោកជា ផ្លារិន ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក៏បានមានប្រសាសន៍ថា មកដល់ដំណាច់ឆ្នាំ ២០១០ កន្លងទៅនេះ កម្ចីរបស់បណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុដែលកំពុងតែមានប្រតិបត្តិការនៅទូទាំង ២៤ខេត្ត និងរាជធានីក្នុងប្រទេស គឺមានទឹកប្រាក់រហូតដល់៣៩២លានដុល្លារ ។ តែក្នុងចំណោមសាច់ប្រាក់នេះវិស័យកសិកម្មទទួលប្រមាណ ៦០% ។

លោកនួន វណ្ណនី ប្រធានផ្នែកទំនាក់ទំនង និងទីផ្សាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រិត បានអះអាងថា មកដល់ពេលនេះអម្រិត មានសាខាប្រតិបត្តិចំនួន៤៩ នៅក្នុងខេត្ត១៤ ហើយមានអតិថិជនជិត ២៤ម៉ឺននាក់ជាមួយនិងប្រាក់កម្ចីដែលមានតម្លៃប្រមាណជា៦៩លាន ។ លោកបានឱ្យដឹងថា នៅក្នុងចំណោមប្រាក់កម្ចីទាំងអស់ប្រាក់កម្ចី ដែលផ្តល់ឱ្យទៅលើវិស័យកសិកម្មមានចំនួន ៦៩% ពាណិជ្ជកម្មប្រមាណជា ១៦% សេវាកម្ម ៣% ផលិតកម្ម៣% ហើយសេវាកម្មប្រាក់កម្ចីផ្សេងៗទៀត មានប្រហែល ៩% ។ លោកក៏បានបញ្ជាក់ថា : "កម្មវិធីឥណទានរបស់យើង គឺដើម្បីជួយប្រជាពលរដ្ឋក្រីក្រនៅតាមតំបន់ជនបទដោយកែប្រែកម្រិតជីវភាពរបស់ពួកគេ" ។ លោកបានឱ្យដឹងថា ដើម្បីទទួលបានឥណទាន ប្រជាពលរដ្ឋគ្រាន់តែទៅទំនាក់ទំនងអាជ្ញាធរមូលដ្ឋាន ពេលនោះភ្នាក់ងារឥណទាននឹងចុះទៅធ្វើការសម្របសម្រួលរៀបចំជូន ។ សំខាន់ ប្រជាពលរដ្ឋដែលត្រូវការទុន ត្រូវតែមានទីលំនៅពិតប្រាកដមានមុខរបរ និងមានផែនការច្បាស់លាស់ ។

## ស្ថាប័នមីក្រូហិរញ្ញវត្ថុពិចារណាបញ្ចុះអត្រាការប្រាក់បន្ថែម

លោកជា ផល្លារិន ប្រធានសាមគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានអះអាងថា ស្ថាប័នមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេស កំពុងតែពិចារណាលើការបញ្ចុះអត្រាការប្រាក់ប្រមាណជា ០.១% ក្នុងមួយខែ ខណៈដែលអត្រាការប្រាក់បច្ចុប្បន្នមានចន្លោះពី ១.៥% ទៅដល់ ៣% ក្នុងមួយខែ។

លោកផល្លារិន បានឱ្យដឹងថា ការបញ្ចុះនេះនៅមិនទាន់ទូលំទូលាយនៅឡើយទេ ដោយសារតែតម្លៃចំណាយផ្សេងៗនៅក្នុងប្រតិបត្តិការ នៅមិនទាន់អនុញ្ញាតឱ្យបញ្ចុះស្រឹប ឬទាំងអស់គ្នានៅឡើយ។ លោកបានឱ្យដឹងដែរថា ការបញ្ចុះអត្រាការប្រាក់នេះ គឺអាចអនុវត្តបានសម្រេចតែឥណទានខ្នាតមធ្យមប៉ុណ្ណោះ សម្រាប់ឥណទានខ្នាតតូច គឺនៅមិនទាន់បានទេ។ ប៉ុន្តែលោកមានជំនឿថា ប្រសិនបើស្ថានភាពសេដ្ឋកិច្ចមានការរីកចម្រើននៅពេលខាងមុខ ហើយប្រាក់បញ្ញើរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុមានកំណើនកើនឡើងទៀតនោះ អត្រាការប្រាក់នឹងអាចបញ្ចុះច្រើនជាងនេះបន្តទៀតដើម្បីស្រួលដល់ការខ្ចី។

# ព័ត៌មានព្រះសហគមន៍កាតូលិក

## នារីជាមាតាក្នុងសង្គមគ្រួសារ និងពិភពលោក

**បាត់ដំបង**

ក្រុមសុខភាពស្ត្រីប្រចាំព្រះសហគមន៍កាតូលិកបាត់ដំបង បានរៀបចំទិវានារីអន្តរជាតិកាលពីថ្ងៃទី៨ខែមីនា នៅក្នុងបរិវេណព្រះសហគមន៍បាត់ដំបង ដោយមានការចូលរួមពីបងប្អូនស្ត្រីៗ ប្រមាណជា២០០នាក់ដែលមកពីក្រុងប៉ោយប៉ែត ប៉ៃលិនស្វាយស៊ីសុផុន តាហែន ទំពូង តាអំ ស្ពៅ រតនមណ្ឌល ច្រាបវាល អូរកំបុត ទេពអ៊ឹម អង្គការអារ៉ូពេ និងបងប្អូនស្ត្រីៗ មកពីបាត់ដំបងផ្ទាល់ផងដែរ ។

អ្នកស្រីគីម ចិន្តា ជាតំណាងអង្គការបន្ទាយស្រីដែលជួយដល់ស្ត្រីមានវិបត្តិនិងរងគ្រោះដោយអំពើហិង្សា និងការពារអនិតិជនមានប្រសាសន៍ដែរថា: "នៅក្នុងឆ្នាំ២០១១នេះ ប្រទេសកម្ពុជាបានផ្តោតសំខាន់ទៅលើនារីវ័យជំទង់ៗ ដោយផ្តល់ឱ្យពួកគេមានសិទ្ធិគ្រប់គ្រាន់ក្នុងការរស់នៅ ការប្រកបការងារ ការបញ្ចេញមតិយោបល់ហើយជាពិសេសសិទ្ធិក្នុងការចូលរួមគ្រប់សកម្មភាពសង្គម" ។ អ្នកស្រីក៏បានបន្តទៀតថា : "នារីទាំងអស់មានសិទ្ធិ ។ ប៉ុន្តែនារីត្រូវប្រើសិទ្ធិរបស់ខ្លួន ឱ្យស្របតាមច្បាប់របស់ប្រទេស និងប្រពៃណីទំនៀមទម្លាប់ខ្មែរយើង" ។

នៅក្នុងឱកាសនោះដែរស្ត្រីទាំងអស់បានចូលរួមសប្បាយជាមួយនិងល្បែងកំសាន្ត រាំរបាំ និងច្រៀងចម្រៀងផ្សេងៗទៀត ដែលបានរៀបចំឡើងដោយក្រុមសុខភាពស្ត្រីនៃព្រះសហគមន៍បាត់ដំបង់ ដែលជាអ្នកដឹកនាំកម្មវិធីទាំងមូល ។ នេះជាឱកាសដែលមានការចោទ ជាសំនួរអំពីសុខភាពស្ត្រី និងទំនាស់ផ្សេងៗនៅក្នុងគ្រួសារ ។



Photo : Battembang

សូមបញ្ជាក់ផងដែរថា កម្មវិធីទិវានារីអន្តរជាតិ ៨ មីនា នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជួយឱ្យស្ត្រីចេះមានការអត់ធ្មត់ ស៊ូទ្រាំ និងជៀសវាងនូវរាល់អំពើហិង្សានៅក្នុងគ្រួសារ ចេះរក្សានូវសុភមង្គល រក្សានូវភាពស្និទ្ធស្នាល និងរក្សាសេចក្តីស្រលាញ់នៅក្នុងក្រុមគ្រួសារ ។

## ព្រះសហគមន៍កាតូលិកកំពង់ចាមកំពុងជំរុញឱ្យយុវជនមានបំណិនជីវិត

ព្រះសហគមន៍តូចមួយដែលឋិតនៅក្នុងភូមិភាគកំពង់ចាម កំពុងតែចូលរួម និងជួយជំរុញលើកទឹកចិត្តឱ្យយុវជនចូលរួមកម្មវិធីអភិវឌ្ឍន៍សហគមន៍ផ្សេងៗ ដើម្បីឱ្យពួកគេមានបំណិនជីវិត ។

លោកសៀម លីវ គ្រូអប់រំជំនឿនៅព្រះសហគមន៍ផ្ទះពេជ្របានមានប្រសាសន៍ថា កាលពីដើមខែមីនាមុននេះ យុវជននៅក្នុងព្រះសហគមន៍និងយុវជននៅក្នុងភូមិ បានចូលរួមជីកស្រះចំនួនបីដែលធ្វើឱ្យពួកគេនឹងមានឱកាសបានរៀបចំការចិញ្ចឹមត្រី ។ គម្រោងនេះមានការ ចូលរួមពីយុវជនប្រមាណ ២៥នាក់ ។

តាមប្រសាសន៍របស់លោកសៀម លីវ ទាំងនេះគឺជាស្រះតូចៗ ដោយស្រះមួយដែលទំហំ ៣ម x ៦ ម មានចំនួន ២ និងស្រះទំហំ ២ម x ៥ម មានចំនួនមួយ ។ ប៉ុន្តែនេះជាកិច្ចខិតខំមួយផ្នែកតូចរបស់ព្រះសហគមន៍ក្នុងការអប់រំយុវជនឱ្យពួកគេចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ដែលធ្វើឱ្យពួកគេអាចទទួលបំណិនជីវិតដែលមានប្រយោជន៍ដើម្បីពួកគេកសាងសង្គមគ្រួសារទៅថ្ងៃអនាគត ។ លោកបានបញ្ជាក់ថា : "ទំហំស្រះនេះ គឺល្មមសម្រាប់ដាក់កូនត្រីបានតែប្រមាណ ពី៥០០ ទៅ៦០០ក្បាល ។ ប៉ុន្តែគម្រោងការធំរបស់យើង គឺផ្តល់នូវជំនាញកសិកម្មដល់យុវជន" ។ លោកបានឱ្យដឹងថា គម្រោងនេះគឺចំណាយថវិកាត្រឹមតែជាង ១០០ដុល្លារ ប៉ុណ្ណោះ ។ តែបើបានជោគជ័យបាននោះ យុវជនអាចរកប្រាក់ចំណូលបានច្រើនលើសពី ១០០ដុល្លារនេះ ដល់ទៅពីរ ទៅបីដងឯណោះ ។

លោកបន្តទៀតថា ការធ្វើកសិកម្មដូចជាចិញ្ចឹមត្រី ដាំបន្លែ ចិញ្ចឹមសត្វ គឺជាជំនាញមួយ ដែលយុវជនគួរតែចូលរួម ព្រោះនេះគឺជាជំនាញដែលពួកគេអាចយកទៅអនុវត្តដោយផ្ទាល់បាននៅតាមសហគមន៍ជាជាងទុកពេលវេលាទំនេរ ទៅប្រព្រឹត្តអំពើផ្សេងៗដែលប៉ះពាល់ដល់សង្គម ។

ព្រះសហគមន៍ផ្ទះពេជ្រ មានសមាជិក ១២នាក់ ឋិតនៅឃុំផ្ទះពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

**ខាន់ ភីរម្យ**

## ទំនាក់ទំនងព្រះសហគមន៍កាតូលិក៥ នៅតំបន់សៀមរាប និងសិង្ហបុរីបានមកពីប្រព័ន្ធផ្សព្វផ្សាយ

អ្នកសម្របសម្រួល ព្រះសហគមន៍ ចំនួន៥ នៅតំបន់សៀមរាប ភូមិភាគបាត់ដំបង បានឱ្យដឹងថា ប្រព័ន្ធផ្សព្វផ្សាយគឺជាស្ពានមួយដ៏ចម្បងក្នុងកិច្ចសហប្រតិបត្តិការពីព្រះសហគមន៍មួយទៅព្រះសហគមន៍មួយទៀត ។

លោកធីម ធន់ គឺជាអ្នកសម្របសម្រួលព្រះសហគមន៍តំបន់សៀមរាប ក៏មានប្រសាសន៍ថា សព្វថ្ងៃនេះព្រះសហគមន៍ចំនួន៥ នៅសៀមរាប គឺសៀមរាប ព្រែកទាល់ ចុងឃ្នៀស តាអំ និងកំពង់ឃ្លាំង កំពុងតែមានកិច្ចសហប្រតិបត្តិការជាមួយព្រះសហគមន៍នៅប្រទេសសិង្ហបុរី ។ លោកធីម ធន់ បញ្ជាក់ថា: "នៅក្នុងរដូវអប់រំពិសេសនេះ យុវជន និងសមាជិកនៃព្រះសហគមន៍សិង្ហបុរីចំនួន ៣៦នាក់ នឹងមកចូលរួមជាមួយយុវជនយើងដើម្បីចូលរួមសម្តែងរឿងព្រះយេស៊ូរងទុក្ខលំបាក ហើយអធិដ្ឋាន និងធ្វើអភិបូជារួមគ្នា ។ ក្រៅអំពីនេះភ្ញៀវយើងទាំង៣៦នាក់នេះ នឹងរួមគ្នាចុះចែកអំណោយជាសម្ភារៈ និងថវិកា ដល់ប្រជាពលរដ្ឋក្រីក្រចំនួន ៥០០គ្រួសារ នៅព្រះសហគមន៍ទាំង៥" ។ លោកធីមធន់បញ្ជាក់ទៀតថា កិច្ចសហប្រតិបត្តិការដែលបានធ្វើរយៈពេល ៥ឆ្នាំមកហើយនេះ ជាផ្លែផ្កាដែលបានមកពីប្រព័ន្ធផ្សព្វផ្សាយ ។

លោកធីម ធន់ ក៏រំឭកថា កាលពីឆ្នាំ២០០៦ ជនជាតិសិង្ហបុរីមួយរូបបានស្គាល់ព្រះសហគមន៍សៀមរាបតាមរយៈការផ្សព្វផ្សាយពីប្រព័ន្ធអ៊ីនធឺណិត ។ កាលនោះគឺជាពេលដែលព្រះសហគមន៍អបអរបុណ្យព្រះយេស៊ូប្រសូត្រ ហើយចាប់ពីពេលនោះមក មិត្តភក្តិរបស់គាត់បានមកចូលរួមសកម្មភាពព្រះសហគមន៍ជាប្រចាំ ។

**ខាន់ ភីរម្យ**

## រៀនអំពីជីវិតក្នុងការត្រាស់ហៅរបស់ព្រះសហគមន៍

**អ៊ឹម សុខន**

អេម៉ាញូអែលជាកម្មវិធីមួយ ដែលស្វែងយល់អំពីជីវិតនៃការត្រាស់ហៅរបស់ព្រះសហគមន៍កាតូលិក សម្រាប់យុវជនដែលចង់យល់ច្បាស់អំពីផ្លូវនៃជីវិតជាអ្នកបួសតាមបែបកាតូលិក ឬហៅថាបូជាចារ្យ តើមានសភាពយ៉ាងណា ?

លោកបូជាចារ្យអ៊ុន សុន ជាអ្នកទទួលខុសត្រូវកម្មវិធីនេះ មានប្រសាសន៍ថា កម្មវិធីនេះមានរយៈពេល ២ឆ្នាំ គឺធ្វើសម្រាប់យុវជនដែលចូលរួមស្វែងយល់អំពីផ្លូវជីវិតរបស់ខ្លួន។ លោកបន្តថា សម្រាប់ឆ្នាំទីមួយ កម្មវិធីអេម៉ាញូអែលមានសិក្ខាប្រធានបទចំនួន៦ផ្សេងគ្នា មានប្រធានបទស្ដីពីព្រះបន្ទូល ប្រវត្តិព្រះសហគមន៍ សេរីភាព អត្តសញ្ញាណឈើឆ្កាង និងការត្រាស់ហៅជាដើម។

លោកអ៊ុន សុនបន្តថា ប្រធានបទទាំង៦នេះនឹងអាចជួយឱ្យយុវជនអាចរិះគិតអំពីផ្លូវជីវិតរបស់ខ្លួនតាមរយៈការស្ដាប់ព្រះបន្ទូល និងបទពិសោធន៍ពីសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន។ ដូច្នេះពួកគេគឺអាចយល់អំពីផ្លូវដើរនៃជីវិតរបស់គេ។

### ត្រូវចេះពឹងផ្អែកលើព្រះយេស៊ូ

ព្រះសហគមន៍កោះរកា ភូមិភាគ កំពង់ចាម មានរៀបចំសិក្ខាសាលា សម្រាប់អស់អ្នកណែនាំជំនឿ ដែលស្ដីអំពីកំណើតព្រះបន្ទូលកាលពីថ្ងៃទី ១-៤ ខែមេសា កន្លងទៅនេះ។

បូជាចារ្យហ្សេរ៉ាល់ វ៉ឺសាំង មានប្រសាសន៍ថា ការបណ្ដុះបណ្ដាលឱ្យមានគរុកោសល្យ គឺជាកត្តាសំខាន់។ ហើយព្រះសហគមន៍នៅបន្តជំរុញបងប្អូនឱ្យចេះរស់នៅពឹងផ្អែកលើព្រះយេស៊ូ ជាពិសេសនៅពេលបងប្អូនជួបការលំបាក។

## ពិធីប្រគល់ និងតែងតាំងនាយិកាថ្មីដែលមានការចូលរួមពីលោកបូជាចារ្យកាតូលិក

ពិធីប្រកាសតែងតាំង នាយិកាថ្មី ជំនួសនាយិកាចាស់ ដែលបានចូលនិវត្តពីសាលាបឋមសិក្សាកោះរកាក្រៅ បានប្រព្រឹត្តិទៅ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១១ នៅក្រោមអធិបតីភាពរបស់លោកឆុន សុយ ប្រធានការិយាល័យអប់រំស្រុក កំពង់សៀម លោកប៊ូ ធី មេឃុំកោះរកាក្រៅ លោកសេរ៉ាល់ដ៏ វ៉ឺសាំង ជាបូជាចារ្យទទួលបន្ទុកព្រះសហគមន៍កោះរកា ព្រមទាំងតំណាងសមាគមមាតាបិតាសិស្ស។

លោកហ៊ីង សុជាតិ ជាអនុប្រធានការិយាល័យអប់រំស្រុក បានអានលិខិតបង្គាប់ក្នុងកិច្ចការងារជានាយិកាសាលាដែលមានខ្លឹមសារសង្ខេបថា : "ក្នុងការគ្រប់គ្រងដើម្បីឱ្យដំណើរការល្អ វាអាស្រ័យទៅលើទំនាក់ទំនងល្អ ហើយធ្វើយ៉ាងណា ? ឱ្យការងារ និងតួនាទីរបស់ខ្លួន មានភាពរីកចម្រើន ដើម្បីជួយបង្កលក្ខណៈ ឬចលនាងាយស្រួលទៅដល់សិស្សានុសិស្សដើម្បីឱ្យសិស្សចូលរៀនបានច្រើន និងក៏ត្រូវមានការប្រាស្រ័យទាក់ទងល្អ ជាមួយនិងសហគមន៍ និងមាតាបិតាសិស្ស ដោយត្រូវធ្វើការទប់ស្កាត់នូវរាល់អំពើហិង្សាទាំងឡាយណា ដែលកើតអាចមានឡើងនៅក្នុងសាលារៀន ជាពិសេស គឺចាប់ផ្ដើមពីលោកគ្រូអ្នកគ្រូ មុនគេ។

សាលាបឋមសិក្សា កោះរកាក្រៅ គឺមានសិស្សសរុបចំនួន ១៨០នាក់ ហើយលោកគ្រូ អ្នកគ្រូ មានចំនួន១១នាក់ បូករួមនិងសិស្សមត្តេយ្យសិក្សាមានចំនួន ៤០នាក់ ព្រមទាំង លោកគ្រូ អ្នកគ្រូ ពីរនាក់ផ្សេងៗទៀត ដែលបង្រៀននៅវេនព្រឹក។

**រ៉េង ឈាន់**

## យុវជនត្រូវចេះធ្វើដំណើរក្នុងផ្លូវ និងជំនឿតែមួយ

កិច្ចប្រជុំលើកទី២ របស់ក្រុមយុវជនដែលត្រៀមចេញទៅចូលរួមទិវាយុវជនពិភពលោក កាលពីថ្ងៃទី២៥-២៧ខែមីនាមុននេះ បានប្រព្រឹត្តទៅនៅព្រះសហគមន៍កោះរកា ភូមិភាគកំពង់ចាម។

លោកផុន សុផល អ្នកសម្របសម្រួលក្រុមយុវជន ដែលត្រៀមចេញទៅចូលរួមទិវាយុវជនពិភពលោកបានមានប្រសាសន៍ថា នៅរាល់ការធ្វើដំណើរម្នាក់ៗតែងអស់កម្លាំងនិងហត់នឿយ។ ប៉ុន្តែយុវជនត្រូវរៀនចេះក្ដាប់កន្ទុវឱកាសរបស់ខ្លួន ដែលមាននៅក្នុងដៃ ពីព្រោះក្រៅពីបរិយាកាស និងការសប្បាយ យុវជនម្នាក់ៗក៏បានស្គាល់មិត្តភក្តិ បរិបទសង្គម និងវប្បធម៌ថ្មី។ លោកបញ្ជាក់ថា: "កិច្ចប្រជុំនេះមានគោលបំណងឱ្យយុវជនដែលមកពីព្រះសហគមន៍គ្រប់តំបន់ទាំងអស់ចំនួន ២៥នាក់នេះ ចេះរួមសុខទុក្ខនឹងគ្នានៅពេលធ្វើដំណើរក្នុងផ្លូវតែមួយ និងជំនឿតែមួយ។

យុវជនហ៊ិន សុភា មកពីព្រះសហគមន៍តាកែវនិយាយថា ពិតណាស់! ខ្ញុំសប្បាយនិងត្រេកអរនៅពេលដែលបានឃើញថា កិច្ចប្រជុំលើកទី២នេះបានជំរុញធ្វើឱ្យទំនាក់ទំនងរបស់យុវជនម្នាក់ៗ កាន់តែមានសាមគ្គីភាពក្នុងការធ្វើកិច្ចការរួមដូចជាការខិតខំសម្ដែងនូវរបាំបង្ហាញអំពីអរិយធម៌ខ្មែរ។

កញ្ញាស៊ុន លីហ្សា យុវនារីមកពីព្រះសហគមន៍ស្អាង ខេត្តកណ្ដាល ក៏បន្ថែមថា អ្វីៗតែរំភើបជាងនេះ គឺខ្ញុំសម្គាល់ថា នាគ្រប់សកម្មភាពការងារទាំងអស់ ដែលយើងធ្វើរួមគ្នានោះ គឺវាពោរពេញដោយស្នាមញញឹម និងការលើកទឹកចិត្ត ដែលនេះបញ្ជាក់យ៉ាងច្បាស់ពីអារម្មណ៍ និងជំហាននៃការទទួលខុសត្រូវ និងគាំទ្រចំពោះគ្នាមិនថា យើងធ្លាប់ ឬពុំធ្លាប់ស្គាល់គ្នាពីមុនមក។

ទិវាយុវជនពិភពលោកលើកនេះនឹងប្រព្រឹត្តិធ្វើឡើងចាប់តាំងពីថ្ងៃទី១៥-២១ខែសីហា ឆ្នាំ២០១១ នៅប្រទេសអេស្ប៉ាញ។

**សុខន**

### ដំណើរទស្សនកិច្ច MEP ទៅកាន់ភូមិភាគកំពង់ចាម

លោកបូជាចារ្យមួយចំនួននៃក្រុមគ្រួសារសាសនទូត អឺមអេភី (MEP) បានចុះសួរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទនៅឯព្រះសហគមន៍កោះរកានៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមកាលពីថ្ងៃទី២ មីនា ឆ្នាំ២០០១។

ដំណើរចុះសាកសួរសុខទុក្ខនេះ ត្រូវបានឡើងក្នុងគោលបំណងលើកទឹកចិត្តប្រជាជននៅក្នុងភូមិកោះរការ និងគ្រីស្តបរិស័ទនៅទីនោះ ហើយដំណើរលើកនេះក៏ដើម្បីជាការផ្ដល់ព័ត៌មាន ឱ្យដល់គ្នាទៅវិញទៅមករវាងលោកបូជាចារ្យ និងអ្នករស់នៅទីនោះ ក្នុងគោលបំណងស្វែងយល់អំពីការរស់នៅរបស់ប្រជាជនដែលរស់នៅក្នុងភូមិ និងក៏ទស្សនារាល់សមិទ្ធិផលទាំងឡាយដែលព្រះសហគមន៍កាតូលិកសម្រេចបានកន្លងមកផងដែរ។

**រ៉េង ឈាន់**

# មនុស្សពេញវ័យ ប្រមាណជា ៣៩៤ នាក់ទទួលការត្រាស់ យ៉ាងឱឡារិក

**លី សុវណ្ណា**

មនុស្សពេញវ័យចំនួនប្រមាណ ៣៩៤នាក់ បានទទួលការត្រាស់ហៅ យ៉ាងឱឡារិក ដោយលោកអភិបាល នៅតាមទីកន្លែងក្នុងព្រះសហគមន៍ភូមិភាគទាំងបីរៀង១ខ្លួន គឺព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមចំនួន ៥៥នាក់ នៅកំពង់ចាម ព្រះសហគមន៍ភូមិភាគបាត់ដំបងចំនួន ១០៤នាក់ នៅបាត់ដំបងទីក្រុង និងព្រះសហគមន៍ ភូមិភាគភ្នំពេញចំនួន ១៣៥នាក់ ដែលប្រារព្ធនៅព្រះវិហារសន្តយ៉ូសែបភ្នំពេញ។

ពិធីនេះប្រារព្ធគឺឡើង កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១១ ជាអាទិត្យទី១នៅក្នុងរដូវអប់រំពិសេស តាមប្រតិទិននៃព្រះសហគមន៍កាតូលិក។

បេក្ខជនដែលត្រាស់ហៅយ៉ាងឱឡារិកគឺជាអ្នកត្រៀមខ្លួនទទួលនូវអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងឆ្នាំ២០១១។

មានប្រសាសន៍ទៅកាន់បេក្ខជន និងគ្រីស្តបរិស័ទ ដែលចូលរួមក្នុងកម្មវិធី លោកអភិបាល សុខកុមារ អូលីវីយ៉េ បានលើកឡើងថា: "នៅថ្ងៃនេះយើងទាំងអស់មានអំណរសប្បាយណាស់ ដោយមានបងប្អូនដែលនឹងទទួលការត្រាស់ហៅជាឱឡារិក ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក គឺទទួលជីវិតអស់កល្បជានិច្ច"។ លោកបន្តថា យើងមានបងប្អូនយ៉ាងច្រើនទទួលការត្រាស់ហៅដែលមិនធ្លាប់មានក្នុងប្រវត្តិព្រះសហគមន៍កាតូលិកនៅកម្ពុជា គឺបងប្អូនមកពីគ្រប់ព្រះសហគមន៍និងមណ្ឌលសកម្មភាពក្នុងភូមិភាគភ្នំពេញ ជាពិសេស សម្រាប់ព្រះសហគមន៍ កោះស្លា ដែលមានបេក្ខជននឹងទទួលនូវអគ្គសញ្ញាជ្រមុជលើកដំបូង។

បងប្អូនបេក្ខជនចំនួន១៣៥នាក់នេះ បានចូលរួមស្តាប់ព្រះបន្ទូលស្គាល់ ព្រះសហគមន៍កាតូលិក ជាយូរឆ្នាំមក ហើយខ្លះ ៦ ទៅ ៧ឆ្នាំ ទើបបានទទួលពិធីត្រាស់ហៅ នៅថ្ងៃនេះ។

យុវតីយ៉ាណា ប៊ូសុភាន បានឱ្យដឹងដែរថា នាងមានអារម្មណ៍រំភើបរីករាយណាស់ ពីព្រោះជាពេលវេលាដែលនាងទន្ទឹងរង់ចាំជាយូរឆ្នាំមកហើយ។ នាងរំភើបដោយនាងជឿថា នាងនឹងទទួលជីវិតថ្មីរួមជាមួយនិងព្រះយេស៊ូ។ នាងបានទទួលស្គាល់ថា ដោយខ្លួនពិការ នាងក៏មានការអស់សង្ឃឹមខ្លាំងក្នុងជីវិត ឆាប់ខឹងច្រើន និងមិនចេះចែករំលែក ជាមួយនរណាឡើយ។ តែក្រោយពេលទទួលនូវការអប់រំជំនឿ និងមានមិត្តភក្តិជាច្រើនយកចិត្តទុកដាក់នឹងរូបនាងនាំឱ្យនាងមាននូវក្តីសង្ឃឹម និងចេះបើកចិត្តទទួលអ្នកដទៃ ជាពិសេស គឺចេះអធិដ្ឋានច្រើន និងយកចិត្តទុកដាក់ចំពោះអ្នកដទៃផងដែរ។

ចំណែកយុវជនស្រៀង លាប បានឱ្យដឹងដែរថា លោកសម្រេចចិត្តទទួលការអប់រំដោយបានឃើញគំរូល្អរបស់គ្រីស្តក្នុងការយកចិត្តទុកដាក់ និងលើកទឹកចិត្តគ្នាទៅវិញទៅមក ជាពិសេស ជួយទៅដល់អ្នកទន់ខ្សោយ។

នៅក្នុងធម្មទេសនា លោកអភិបាលសុខកុមារ អូលីវីយ៉េ ក៏រំឭកដល់បងប្អូនបេក្ខជន និងគ្រីស្តបរិស័ទទាំងអស់ឱ្យចាប់អារម្មណ៍នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក គឺទទួលព្រះកាយព្រះគ្រីស្តរួមគ្នានៅក្នុងព្រះសហគមន៍។ ធ្វើជាគ្រីស្តបរិស័ទ ត្រូវយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលខិតខំរស់នៅតាមព្រះបន្ទូល គឺនាំឱ្យព្រះបន្ទូលបានចូលក្នុងចិត្តរបស់ខ្លួន។ ម្យ៉ាងទៀត គឺរស់នៅដូចជាបងប្អូន នៅក្នុងគ្រួសារតែមួយ គោរពគ្នាស្រឡាញ់ និងលើកលែងទោសឱ្យគ្នានិងចេះសហការគ្នាល្អដើម្បីធ្វើជាសញ្ញាសម្គាល់អំពីព្រះយេស៊ូគង់ជាមួយយើង ហើយព្រះសហគមន៍ពិតជាព្រះកាយព្រះគ្រីស្តប្រាកដមែន។



Photo : L. Sovanna

# បងស្រីយីង លូស៊ី : "កុំខ្លាចអ្វី! ខ្ញុំតែងនាំមុខអ្នកជានិច្ច"

**អ៊ឹម សុខន**



Photo : Humanity

"គ្រប់សកម្មភាពដែលខ្ញុំធ្វើ គឺពុំមែនឱ្យអ្នកទាំងអស់គ្នារត់តាមខ្ញុំទេ តែដើម្បីឱ្យអ្នករាល់គ្នាយល់ពីតម្លៃនៃសេចក្តីពិតដែលមានចំពោះយើងម្នាក់ៗ"។ នេះជាប្រសាសន៍បងស្រីវ៉ង់មែនយីងលូស៊ី ជាសមាជិកក្រុមសាសនទូតគ្រីស្តបរិស័ទក្រុងហុងកុង។

បងស្រីលូស៊ី ដែលបានបញ្ចប់នូវបេសកកម្មនៅកម្ពុជាម្តងហើយនៅឆ្នាំ២០០៨ រៀបរាប់ថា ការវិលមកកម្ពុជាម្តងទៀតរបស់ខ្ញុំ ជាការរៀបចំរបស់ព្រះជាម្ចាស់ ទោះបីខ្ញុំមកដោយការចាត់តាំងរបស់ក្រុម និងអង្គការមនុស្សលោកថ្មីក៏ដោយ។

បងស្រីវ៉ង់មែន យីងលូស៊ី បានមកបម្រើការនៅប្រទេសកម្ពុជាម្តងពីឆ្នាំ១៩៩៩-២០០៨។ បងស្រីបានធ្វើការជាមួយអង្គការមនុស្សលោកថ្មីលើកម្ម-វិធីអភិវឌ្ឍន៍ជនបទ ដែលផ្តោតជាសំខាន់លើវិស័យអប់រំ។ ពេលនោះបងស្រីក៏ធ្វើជាគ្រូបង្រៀនភាសាអង់គ្លេសនៅវិទ្យាស្ថានភាសាបរទេសភ្នំពេញ និងគ្រូស្ម័គ្រចិត្តនៅតាមភូមិក្នុងខេត្តកណ្តាលផងដែរ។

សាសនទូតរូបនេះមានប្រសាសន៍ថា : "កិច្ចការនេះពុំមែនងាយស្រួលសម្រាប់យើងជាជនបរទេសនោះឡើយ។ ប៉ុន្តែយើងត្រូវយកចិត្តទុកដាក់ និងមានភាពអត់ធ្មត់គ្រប់សកម្មភាព ដែលនាំយើងឱ្យយល់អំពីតម្លៃរបស់ការងារ និងការអប់រំ។ ប៉ុន្តែអ្វីដែលខ្ញុំជឿ និងទុកចិត្តបំផុតនោះ គឺព្រះជាម្ចាស់។ ព្រះអង្គតែងគង់ជាមួយខ្ញុំ និងដឹកនាំខ្ញុំ ឱ្យដើរតាមសេចក្តីពិតសម្រាប់គ្រប់កិច្ចការទាំងអស់របស់ខ្ញុំ។

ពីឆ្នាំ២០០០-២០០៤ បងស្រីលូស៊ី ក៏បានធ្វើជាអនុប្រធានមណ្ឌលនិស្សិតកាតូលិកកម្ពុជា និងក៏ជាពេលដែលបងស្រី បានធ្វើការស្ម័គ្រក្នុងក្រុមគ្រួសារសហជីវិនព្រះយេស៊ូផងដែរ។ តែនៅចុងឆ្នាំ២០០៤ បងស្រីត្រូវក្រុមគ្រួសារប្តូរការងារ ឱ្យទៅបង្រៀនឯប្រទេសចិនរហូតដល់ឆ្នាំដើមឆ្នាំ២០០៨។ តែខែមករា ឆ្នាំ២០០៩ បងស្រីត្រូវបានក្រុមប្តូរឱ្យមកបម្រើព្រះសហគមន៍កម្ពុជាជាថ្មីម្តងទៀត។

បងស្រីមានប្រសាសន៍ថា : "កិច្ចការ ដែលខ្ញុំធ្វើជាមួយអង្គការមនុស្សលោកថ្មី និងរដ្ឋាភិបាល ក្នុងនាម ជាអ្នកបណ្តុះបណ្តាលគ្រូមត្តេយ្យ ខ្ញុំក៏រីករាយត្បិតវាមិនត្រឹមជាកិច្ចការ ដែលជាជំនាញរបស់ខ្ញុំទេ តែជាកិច្ចការដែលបង្រៀនឱ្យខ្ញុំចេះជ្រើសរើសយកមាគ៌ានៃព្រះយេស៊ូ។ បងស្រីបញ្ជាក់ថា: "ព្រះអង្គបង្រៀនខ្ញុំថាកុំខ្លាចអ្វី! ខ្ញុំតែងតែនាំមុខអ្នក ជានិច្ច"។ ពេលនេះ ខ្ញុំសប្បាយចិត្តនឹងកិច្ចការដែលខ្ញុំធ្វើ ទោះបីជាខ្ញុំរស់ នៅខេត្តកំពង់ឆ្នាំង និង១ខែម្តងទៅធ្វើបង្រៀនគ្រូនៅខេត្តមណ្ឌលគិរីក៏ដោយ។ ខ្ញុំរីករាយនឹងកិច្ចការដែលព្រះជាម្ចាស់ចាត់ឱ្យខ្ញុំធ្វើ។ ខ្ញុំយល់ថាខ្ញុំអាចជោគជ័យទៅបាន ទាល់តែខ្ញុំមានភាពស្មោះត្រង់នឹងការងារ និងមិត្តរួមការងារ។

## ព្រះជាម្ចាស់ត្រាស់ហៅបងប្អូន ១០៤នាក់ ឱ្យទទួលជំហានទី២ នៅព្រះសហគមន៍បាត់ដំបង

ពិធីទទួលជំហានទី២របស់បងប្អូន ១០៤នាក់ បានប្រារព្ធកាលពីថ្ងៃអាទិត្យទី១៣ មីនា ឆ្នាំ២០១១ នៅព្រះសហគមន៍កាតូលិកបាត់ដំបង ដោយមានការចូលរួមពីលោកបូជាចារ្យ ៧អង្គ គឺមានលោកអភិបាលគីកេ លោកបូជាចារ្យតូតែត លោកបូជាចារ្យហ្គេក ណាល់ លោកបូជាចារ្យហ្វ្រង់កូ លោកបូជាចារ្យចាប់ លោកបូជាចារ្យវ៉ាជិក និងលោកបូជាចារ្យដេវីឌ ចន។

បងប្អូនទាំង១០៤នាក់នេះ មកពីព្រះសហគមន៍ផ្សេងៗនៅក្នុងភូមិភាគបាត់ដំបង ដូចជា ពោធិ៍សាត់ ស្វាយស៊ីសុផុន ប៉ោយប៉ែត និគម ចំណោម ស្ទុង ប៉ៃលិន កំពង់ឆ្នាំង តាហែន ខ្នាច រមាសតាពូង កំពង់រទេះ និងព្រះសហគមន៍កាតូលិកបាត់ដំបង។

លោកគីកេ ហ្វីការេដូ អភិបាលព្រះសហគមន៍ភូមិភាគកាតូលិកបាត់ដំបង មានប្រសាសន៍ថា : "កាលពីមុនយើងទទួលជំហានទី១ យើងយកព្រះគម្ពីរ និងព្រះសហគមន៍ជាទីពឹង និងយកព្រះយេស៊ូជាគំរូ។ ប៉ុន្តែលើកនេះ យើងត្រូវឱ្យយល់ជ្រៅជាងដើម្បីដើរតាមព្រះមាគ៌ារបស់ព្រះជាម្ចាស់"។

កញ្ញាកាំង យូរី ពីព្រះសហគមន៍កំពងរទេះនិយាយថា : "ខ្ញុំតស៊ូរៀនអប់រំរហូតដល់បានទទួលជំហានទី២នេះព្រោះខ្ញុំចង់ស្គាល់ព្រះយេស៊ូ។ ខ្ញុំស្រលាញ់ព្រះយេស៊ូ និងចង់ដើរតាមព្រះអង្គ"។ ចំណែកយុវជនជាសុវណ្ណារដ្ឋ អាយុ ១៨ឆ្នាំ មកពីព្រះសហគមន៍កំពង់ឆ្នាំង បាននិយាយថា : "ខ្ញុំមានជំនឿលើព្រះយេស៊ូពីព្រោះខ្ញុំគិតថា ព្រះអង្គជាផ្លូវនៃជីវិតរបស់ខ្ញុំ"។



Photo : Battembang

**អាន ឫទ្ធីរដ្ឋ**

# លីប៊ី ស្ថិតនៅក្នុងភាពចលាចលដោយសង្គ្រាមស៊ីវិល

**ជាត សំភី**





Photos : DR

ដែនដីរបស់ប្រទេសលីប៊ី បានធ្វើអាណានិគមនាសម័យបុរាណដោយជនជាតិ ហ្វេនីស្យាង ដែលជាប្រជាជនបុរាណ មានជំនាញខាងដើរនាវា និងធ្វើជំនួញ។បន្ទាប់មកប្រទេសលីប៊ីត្រូវធ្លាក់ទៅក្រោមអាណានិគមរបស់ក្រិក នៅមុនពេលត្រូវបានត្រួតត្រា ដោយចក្រភពរ៉ូម៉ាំង។

នាសតវត្សរ៍ទី៧ ប្រទេសលីប៊ីបានត្រូវលុកលុយដោយកងទ័ពអារ៉ាប់។ ដូច្នេះហើយទើប ប្រជាជនលីប៊ីភាគច្រើនមានវប្បធម៌អារ៉ាប់ ហើយប្រជាជនស្ទើរតែទាំងអស់មានជំនឿលើសាសនាឥស្លាមស៊ុននីត។ បន្ទាប់ពីបានបែងចែកជាច្រើនព្រះរាជាណាចក្រនាកាលមជ្ឈិមសម័យ ប្រទេសលីប៊ីក៏ត្រូវធ្លាក់នៅ ក្រោមការត្រួតត្រារបស់ចក្រភពអូតូម៉ង់ នៅសតវត្សរ៍ទី១៦។

ប្រទេសលីប៊ី ជាកម្មសិទ្ធចុងក្រោយរបស់ចក្រភពអូតូម៉ងនៅទ្វីបអាហ្វ្រិក ប៉ុន្តែត្រូវបានវាយត្រួតត្រា និងធ្វើអាណានិគមដោយព្រះរាជាណាចក្រអ៊ីតាលីនៅឆ្នាំ១៩១២។

នៅឆ្នាំ១៩៥១ បន្ទាប់ពីសង្គ្រាមលោកលើកទី២ លីប៊ី បានប្រកាសនូវឯករាជ្យភាពរបស់ខ្លួន ក្រោមទម្រង់ជារាជាណាចក្រដែលដឹកនាំដោយព្រះមហាក្សត្រព្រះនាមអ៊ីឌ្រី ទីមួយ។ ប៉ុន្តែព្រះអង្គត្រូវបានរំលំចេញពីអំណាចដោយសារតែរដ្ឋប្រហារយោធាមួយ នៅឆ្នាំ១៩៦៩។

បន្ទាប់មកលីប៊ីក៏ត្រូវបានដឹកនាំដោយលោកម៉ូអាមម៉ារ កាដាហ្វីដែលជាមេបញ្ជាការកងទ័ពមួយរូបអាយុ២៧ឆ្នាំ ដែលប្រកាសដោយស្វ័យប្រវត្តិថាជាវីរៈសេនីយ៍ឯក។ លោកបានអភិវឌ្ឍនយោបាយហៅថា ប៉ាណារ៉ាបីស្ម៍ ដែលគឺជាចលនានយោបាយវប្បធម៌ និងមនោគមវិជ្ជា... ដែលសំដៅទៅរកការបង្រួបបង្រួមប្រជាជនអារ៉ាប់។

បើនិយាយអំពីសេដ្ឋកិច្ច នៅឆ្នាំ២០០៩ ផលិតផលជាតិសរុប (PNB) របស់លីប៊ីបានកើនដល់ ៦២ កោដិដុល្លារ ផលិតផលជាតិសរុបនៃប្រជាជនម្នាក់ៗគឺ១២,០២០ដុល្លារ ធ្វើឱ្យលីប៊ីស្ថិតនៅក្នុងចំណោម៥០ប្រទេស រុងរឿងជាងគេ នៅលើពិភពលោក។ សេដ្ឋកិច្ចលីប៊ីពឹងផ្អែកលើការនាំចេញប្រេងគឺ៩៥% នៃការនាំចេញសរុប។ លីប៊ីជាប្រទេសផលិតប្រេងលំដាប់ទីពីរ នៅក្នុងទ្វីបអាហ្វ្រិកគឺបន្ទាប់ពីប្រទេសនីហ្សេរីយ៉ានិងនាំមុខប្រទេសអាល់ហ្សេរី។ តែលីប៊ីមានប្រេងបម្រុងធំបំផុតនៅទ្វីបអាហ្វ្រិក។ ប្រេងបម្រុងរបស់លីប៊ីត្រូវ គេប៉ាន់ប្រមាណមាន ៤៦,៤ កោដិបារ៉ែល។ ដូច្នេះប្រទេសលីប៊ីស្ថិតក្នុងចំណោមតួអង្គសំខាន់ៗ នៃអង្គការប្រទេសនាំចេញប្រេងអូពិច (OPEP)។

ប្រេងរបស់លីប៊ី គឺជាប្រេងដែលមានគុណភាពមិនថ្លៃ ក្នុងការផលិត និងនៅជិតមណ្ឌលប្រើប្រាស់ (អឺរ៉ុប)។ តែសមត្ថភាពផលិតត្រូវបានធ្វើឱ្យពិការមួយផ្នែកដោយសារតែភាពទន់ខ្សោយនៃការវិនិយោគ និងការហ៊ុមព័ទ្ធសេដ្ឋកិច្ច តាមរយៈទណ្ឌកម្មសេដ្ឋកិច្ច ដែលសម្រេចដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិនៅឆ្នាំ១៩៨៦។

នៅឆ្នាំ២០១១ ប្រទេសលីប៊ីក៏ទទួលរងកុបកម្ម និងចលាចលជាច្រើន ទន្ទឹមនឹងចលនាតវ៉ា នៅក្នុងប្រទេសអារ៉ាប់។ តែកុបកម្ម និងចលាចលទាំងនេះបានប្រែក្លាយឱ្យទៅជាសង្គ្រាមស៊ីវិលដ៏ពិតប្រាកដ១។ ទាំងខាងប្រឆាំង និងគាំទ្រលោកកាដាហ្វីបានប្រើប្រាស់អាវុធធុនធ្ងន់ដូចជារថក្រោះ ហើយខាងលោកកាដាហ្វីមានយន្តហោះទម្លាក់គ្រាប់បែក។

ការបះបោរលីប៊ី ជាចលនាតវ៉ាប្រជាជនជាមួយនិងការទាមទារនូវសិទ្ធិខាងសង្គម និងនយោបាយដែលចាប់ផ្តើមនៅថ្ងៃទី១៥ កុម្ភៈ ឆ្នាំ២០១១។ ដូចនៅប្រទេសទុយនេស៊ី និងអេហ្ស៊ីបអ្នកតវ៉ាទាមទារឱ្យកាន់តែមានសេរីភាព និងប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្ស ឱ្យបានល្អប្រសើរ...។

សព្វថ្ងៃនេះលីប៊ីកំពុងទទួលរងការវាយប្រហារពីបស្ចិមប្រទេស មានបារាំង អង់គ្លេស និងអាម៉េរិក... ក្នុងមូលហេតុការពារប្រជាជន។



### តើលីប៊ីស្ថិតនៅទីណា?

ប្រទេសលីប៊ីមានឈ្មោះជាផ្លូវការថា មហា ជីម៉ាហ៊ីរីយ៉ាអារ៉ាប់ លីប៊ី ប្រជាមានិតសង្គមនិយម។ នេះជាប្រទេសមួយនៅអាហ្វ្រិកខាងជើង ដែលមានព្រំដែនភាគខាងជើងជាប់នឹងសមុទ្រមេឌីទែរ៉ាណេ។ ភាគខាងលិចជាប់នឹងប្រទេសអាល់ហ្សេរី និងទុយនេស៊ី។ ខាងត្បូងជាប់ និងប្រទេសនីហ្សេ និងប្រទេសឆាត និងខាងកើតជាប់នឹងប្រទេសស៊ូដង់ និងប្រទេសអេហ្ស៊ីប។ ប្រទេសនេះមានផ្ទៃក្រឡា ១,៧៥៩,៥៤០គម$^2$ និងមានប្រជាជនប្រមាណ ៦,១៧៣,៥៧៩នាក់ (ឆ្នាំ២០០៨)។ ប្រជាជនរស់នៅប្រមូលផ្តុំនៅតាមឆ្នេរ។ ចំណែកផ្នែកខាងក្នុងនៃប្រទេសគឺជាវាលលំហ។ រាជធានី ហៅថាទ្រីប៉ូលី។ ភាសាផ្លូវការ គឺអារ៉ាប់ និងប្រើប្រាស់រូបិយបណ្ណឌីណា លីប៊ី (Dinar libyen)។



Photo : S. Philong

# ព្រឹទ្ធាចារ្យ: "អាចារ្យគួរតែរៀនក្បួនខ្នាត"

**ខាន់ ភីរម្យ**

លោកនូវ វណ្ណ ព្រឹទ្ធាចារ្យមួយរូប មានប្រសាសន៍ថា អាចារ្យគួរតែរៀនក្បួនខ្នាតឱ្យបានច្បាស់លាស់ ក្នុងមុខងារជាអាចារ្យ បើមិនដូច្នេះទេ អាចារ្យមួយចំនួនអាចនឹងធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ និងប្រពៃណីដ៏ថ្លៃថ្លារបស់ខ្មែរ ដែលបន្សល់ទុកមកតាំងពីយូរយារណាស់មកហើយ។

ព្រឹទ្ធាចារ្យក៏បានឱ្យដឹងថា អាចារ្យគឺជាតំណាងឱ្យចាស់ព្រឹទ្ធាចារ្យ ដែលដឹកនាំពិធីនានា តាមផ្លូវព្រះពុទ្ធសាសនា។ ដូច្នេះបើមនុស្សម្នាក់ ពុំមានចំណេះដឹងច្បាស់លាស់ ហើយតាំងខ្លួន ធ្វើជាអាចារ្យទៅដឹកនាំពិធីផ្សេងៗ អាចនឹងធ្វើឱ្យវប្បធម៌ និងប្រពៃណីបាត់បង់ទៅតាមនោះ ហើយវប្បធម៌ និងប្រពៃណីទាំងនេះនឹងមានការបាត់បង់នូវសណ្តាប់ធ្នាប់នៅក្នុងសាសនាផងដែរ។

ព្រឹទ្ធាចារ្យក៏បានបញ្ជាក់ថា: "ដើម្បីធ្វើជាអាចារ្យមួយរូបបាន ទាល់តែយើងធ្លាប់បួសរៀន និងចេះព្រះធម៌"។

ព្រឹទ្ធាចារ្យ លើកឧទាហរណ៍ថា បុណ្យកត្តញ្ញូមួយ បើពុទ្ធបរិស័ទអញ្ជើញយើង ឱ្យទៅធ្វើអាចារ្យ យើងត្រូវតែដឹងខ្លួនឯង ឱ្យច្បាស់ថា តើពិធីនោះគេត្រូវធ្វើយ៉ាងម៉េច? ត្រូវការសម្ភារៈអ្វីខ្លះ? ហើយត្រូវចេញ ឬផ្តើមពីចំណុចណាឱ្យច្បាស់លាស់ដែរ ដោយមិនមែនចេះតែធ្វើតាមទឹកឃើញនោះទេ។

លោកបានបន្តទៀតដែរថា ដើម្បីរៀបចំបុណ្យនេះបាននោះ គេតម្រូវឱ្យមានតាំងពីសម្លៀកបំពាក់ថ្មីមួយសម្រាប់បុស្បុក បាត ឬក្អមជាដើម។

ពាក់ព័ន្ធទៅនឹងការដែលក្រសួងធម្មការ និងកិច្ចការសាសនា ដែលជំរុញឱ្យអាចារ្យនៅទូទាំងប្រទេស ត្រូវចូលរួមវគ្គបណ្តុះបណ្តាលកាលពីឆ្នាំទៅនោះ លោកព្រឹទ្ធាចារ្យនូវ វណ្ណ បានគាំទ្រ ហើយលោកក៏បានមានប្រសាសន៍ថា រូបខ្លួនលោកផ្ទាល់ក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលមួយដែលគេបានរៀបចំឡើងកាលពីឆ្នាំ២០១០កន្លងទៅ។

លោកព្រឹទ្ធាចារ្យ ក៏បានឱ្យដឹងទៀតផងដែរថា អាចារ្យគឺជាមនុស្ស។ ដូច្នេះនេះមិនប្រាកដថា ឱ្យតែអាចារ្យ សុទ្ធតែដឹងអំពីតួនាទី និងក្រឹត្យក្រមអាចារ្យ ទាំងអស់នោះទេ។ ដូច្នេះការដែលក្រសួងបណ្តុះបណ្តាលអាចារ្យនោះ គឺជាការត្រឹមត្រូវ ។

លោកព្រឹទ្ធាចារ្យ បញ្ជាក់ថា កាលពេលដែលលោកបានចូលរួមវគ្គបណ្តុះបណ្តាលធ្វើអាចារ្យ ដែលរៀបចំឡើងដោយក្រសួងធម្មការ និងកិច្ចការសាសនា គឺមានចំណុចល្អមួយចំនួនដូចជា ទទួលសីលធម៌អាចារ្យ ចំណេះដឹងទូទៅ និងក្បួនច្បាប់ខ្លះៗ។

អំណាន

## រឿងជួបតែក្រ




កំសត់ជាបញ្ញវន្ត ដែលទើបនឹងរៀនចប់ពីសកលវិទ្យាល័យថ្មីៗ តែពុំអាចរកការងារធ្វើបាន។ ដូច្នេះគេទៅធ្វើជាអ្នកស្ម័គ្រចិត្តនៅឯស្ថាប័នមួយដែលស្វែងរកជំនួយពីខាងក្រៅប្រទេសដើម្បីជួយអ្នកក្រីក្រ។

តាំងពីពេលនោះមក ទាំងដើរ ទាំងដេកទាំងអង្គុយ គេជួប និងឃើញតែអ្នកក្រ: អ្នកក្រដែលថារូបគេយកឈ្មោះអ្នកក្រទៅសុំលុយបរទេស អ្នកក្រដែលបដិសេធមិនបញ្ជូនកូនចៅឱ្យទៅរៀន អ្នកក្រដែលខំធ្វើជាងឃឹតល្ងង់ដើម្បីសុំលុយដោយសារតែដីស្រែផ្ទះត្រូវគេរឹបអូស ឬឈូសចោល អ្នកក្រដែលផឹកស្រាស្អុយហួង ហើយក៏ដើរសម្លុតគេយកលុយ និងអ្នកក្រដែលបានប្ដីពិការបន្សល់ពីសង្គ្រាម-ល-។

"ជួបតែក្រ" និពន្ធដោយលោកហែម សុបិន្ត ក្នុងកម្រងរឿងដែលមានចំណងថា "ស្នេហាខ្ញុំ"។ នេះជារឿងទស្សនវិជ្ជា ដែលធ្វើវិភាគយ៉ាងល្អិតល្អន់លើសង្គមកម្ពុជាបច្ចុប្បន្នជុំវិញភាពក្រីក្រ: ការរើសអើង គម្លាតយ៉ាងមហិមារវាងអ្នកមាន និងអ្នកក្រ ជាមួយឧត្តមគតិដ៏ខ្ពង់ខ្ពស់នៃនិស្សិតបញ្ញវន្ត។ ប៉ុន្តែពួកគេប្រឈមនឹងភាពអត់ការងារធ្វើ។

## រឿងចម្រៀងអរុណោទ័យ




រឿងចំរៀងអរុណោទ័យ គឺជាប្រលោមលោក ដ៏ល្បីល្បាញ ដែលទទួលបានពានរង្វាន់លេខមួយក្នុងការប្រកួតប្រជែងអក្សរសិល្ប៍អន្តរសាសន៍របស់កុមារ ដោយសារតែប្រធានបទដ៏ល្អគឺ "ការតស៊ូ និងភាពមានៈរបស់កុមារីជនបទម្នាក់ដែលចង់បន្តការសិក្សានៅទីក្រុង ខណៈដែលអ្នកជុំវិញថា នេះជាគំនិតលីលាមួយ។

នៅអាយុ១៤ឆ្នាំដាវ៉ាន់ រៀនចប់អនុវិទ្យាល័យនៅភូមិរបស់នាង ដែលស្ថិតនៅក្នុងទីជនបទមួយនៃប្រទេសភូមា ដោយពុះពារឧបសគ្គរាប់មិនអស់ដោយសារតែគ្រួសារក្រីក្រ និងទំនៀមទម្លាប់ដែលមិនបញ្ជូនកូនស្រីទៅសាលា។ តែនៅវិទ្យាល័យតម្រូវឱ្យបង់ប្រាក់។ នៅពេលដែលដាវ៉ាន់ប្រលងបានទទួលអាហារូបករណ៍បានហើយ ឪពុកនាងចង់ឱ្យប្អូនប្រុសដែលរៀនបានលេខពីរទៅរៀនជំនួសវិញ។ "ហេតុផលរបស់គាត់គឺមានតែមួយគត់" គឺដោយសារតែដាវ៉ាន់ជាក្មេងស្រី! តើដាវ៉ាន់ត្រូវធ្វើដូចម្តេច?

ចំណងជើងរឿងជាភាសាអង់គ្លេស "Sing to the Dawn" និពន្ធដោយមីងហ្វុងហ៊ូ និងបកប្រែដោយរ៉ឹង ចាន់ដារ៉ា។

**ហួត សុជាតា**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

## ខែមេសា ២០១១ លោកជួន សាខន ប្រធានមណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា



**សប្តាហ៍ទី៤ ក្នុងរដូវអប់រំពិសេស ឬរដូវ ៤០ថ្ងៃ (ថ្ងៃទី៣ ខែមេសា ២០១១) (*យ៉ូហាន ៩,១-១៤*)**

លោកយ៉ូហានជាសាក្សីផ្ទាល់ភ្នែកឃើញព្រះយេស៊ូធ្វើការអស្ចារ្យនេះនៅក្រុងយេរូសាឡឹម ។ គាត់ថែងរឿងដ៏រំភើបនេះដើម្បីបញ្ជាក់ថា ព្រះយេស៊ូពោរពេញដោយព្រះហឫទ័យប្រណីសន្តោស ។ ព្រះអង្គជា "ព្រះពន្លឺនៃពិភពលោក" ។ អ្នកខ្វាក់ពីកំណើតមិនគ្រាន់តែភ្លឺភ្នែកប៉ុណ្ណោះទេតែគាត់ទទួលពន្លឺខាងជំនឿដែរ ។ ពួកផារាស៊ីដែលមានចិត្តក្រអឺតក្រទម ។ គេមិនអាចស្គាល់ "បុត្រមនុស្ស" ដ៏សុភាពដែលអ្នកស្រុករង់ចាំជាយូរ មកហើយនោះទេ ។

ក្នុងអាទិត្យនេះ យើងជាគ្រីស្តបរិស័ទរួមជាមួយអស់បងប្អូនដែលទទួលការអប់រំពិសេស ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងត្រូវតែជម្រះចិត្តគំនិតពីភាពក្រអឺតក្រទមរបស់ខ្លួនដើម្បីអាចទទួលព្រះជន្មដ៏រុងរឿង ដែលព្រះយេស៊ូប្រទានឱ្យមនុស្សយើងក្នុងឱកាសបុណ្យចម្លងនេះបានដោយសមរម្យ ។

**សប្តាហ៍ទី៥ ក្នុងរដូវអប់រំពិសេស ឬរដូវ៤០ថ្ងៃ (ថ្ងៃទី១០ ខែមេសា ២០១១) *យ៉ូហាន (១១,១-៤៥)***

គួរឱ្យឆ្ងល់ជាខ្លាំង ពេលព្រះយេស៊ូទទួលដំណឹងថា ឡាសារជាមិត្តសម្លាញ់ឈឺធ្ងន់ ហេតុអ្វីក៏ព្រះអង្គមិនប្រញាប់យាងទៅប្រោសគាត់ភ្លាម ហើយបែរជាមានព្រះបន្ទូលថា: "ជំងឺនេះមិនបណ្តាលឱ្យគាត់ស្លាប់ទេ គឺដើម្បីលើកតម្កើងព្រះជាម្ចាស់ និងឱ្យព្រះបុត្រារបស់ព្រះអង្គសម្តែងសិរីរុងរឿងវិញ" ។

ចំពោះព្រះយេស៊ូ ស្លាប់មិនមែនជាទីបញ្ចប់ទេ ។ ព្រះអង្គប្រោសលោកឡាសារឱ្យរស់ឡើងវិញ ដើម្បីបង្ហាញថា ព្រះជាម្ចាស់ជាអម្ចាស់លើជីវិត និងលើសេចក្តីស្លាប់ ហើយក៏ជាសញ្ញាមួយបញ្ជាក់ថា ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ថា ប្រោសអស់អ្នកស្លាប់ក្នុងព្រះគ្រីស្តឱ្យទទួលជីវិតអស់កល្បជានិច្ចនោះ បានកើតជារូបរាងហើយ ។ ក្នុងអាទិត្យនេះ យើងជាគ្រីស្តបរិស័ទ រួមជាមួយអស់បងប្អូនដែលទទួលការអប់រំពិសេស ត្រូវតែជម្រះចិត្តគំនិតរបស់ខ្លួនពីភាពភ័យខ្លាចគ្រប់យ៉ាងដើម្បីអាចទទួលជីវិតថ្មីពីព្រះយេស៊ូក្នុងឱកាសបុណ្យចម្លងខាងមុខនេះបានដោយសមរម្យ ។

**បុណ្យលើកតម្កើងទុក្ខលំបាករបស់ព្រះយេស៊ូ (ថ្ងៃទី១៧ ខែមេសា ២០១១) *ម៉ាថាយ (២៦,១៤-២៧,៦៦)***

ថ្ងៃអាទិត្យហែស្លឹកនេះគឺផ្តើមចូលក្នុងសប្តាហ៍ពិសិដ្ឋ ហើយជាឱកាសឱ្យយើងរំឭកអំពីជម្រៅនៃជំនឿរបស់ខ្លួនអំពីព្រះបន្ទូល និងអំពីកិច្ចការដែលព្រះអម្ចាស់យេស៊ូបានប្រព្រឹត្តក្នុងអាទិត្យចុងក្រោយបង្អស់មុនគេធ្វើគុតព្រះអង្គ ។

ថ្ងៃអាទិត្យនេះ យើងសប្បាយរួមជាមួយព្រះយេស៊ូយាងចូលទីក្រុងដ៏វិសុទ្ធ ក្នុងឋានៈជាព្រះមហាក្សត្រ យាងមកគ្រងរាជ្យក្នុងមហាបេសកកម្មសង្គ្រោះមនុស្សលោកតាមរយៈព្រះអង្គរងទុក្ខលំបាកសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿងពីព្រះបិតា ។ ចូរយើងអបអរសាទរព្រះគ្រីស្តជាព្រះមហាក្សត្រយើង ! ចូរយាងព្រះអង្គគង់ក្នុងចិត្តក្នុងគ្រួសារយើង ដើម្បីព្រះអង្គណែនាំ និងថែរក្សា ។ ប៉ុន្តែបន្ទាប់ពីថ្ងៃអាទិត្យដ៏សប្បាយនេះទៅ គឺជាពេលដែលយើងចូលរួមនឹងទុក្ខលំបាករបស់ព្រះអង្គ ។ ទុក្ខលំបាករបស់ព្រះគ្រីស្តបានផ្លាស់ប្រែទំនាក់ទំនងរវាងមនុស្សនឹងព្រះជាម្ចាស់ និងរវាងមនុស្សនឹងមនុស្សដែរ ។

**បុណ្យចម្លង ព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង (ថ្ងៃទី២៤ ខែមេសា ២០១១) *យ៉ូហាន (២០,១-៩)***

ព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង បន្ទាប់ពីព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គតយ៉ាងសែនអាម៉ាស់នៅលើឈើឆ្កាង ។ ព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿង គឺព្រះអង្គឈ្នះបាប និងសេចក្តីស្លាប់ ។ មនុស្សយើងគ្រប់ៗរូប ទោះជាអ្នកប្រព្រឹត្តតាមសាសនា ឬមិនកាន់សាសនាក៏ដោយ ក៏មានបំណងប្រាថ្នាកប់យ៉ាងជ្រៅក្នុងចិត្ត ចង់ឈ្នះបាប និងសេចក្តីស្លាប់នោះដែរ ។ គ្រីស្តបរិស័ទមានអំណរសប្បាយយ៉ាងខ្លាំង ត្បិតព្រះយេស៊ូក៏ប្រោសខ្លួនឱ្យឈ្នះបាប និងសេចក្តីស្លាប់រួមជាមួយព្រះអង្គទុកជាព្រះអំណោយទាន ។ គ្រីស្តបរិស័ទតែងតែចែកអំណរសប្បាយដែលខ្លួនមាននោះដល់អ្នកឯទៀតៗជានិច្ច ត្បិតជាកាតព្វកិច្ចដែលខ្លួនត្រូវតែប្រព្រឹត្តតាមព្រះបញ្ជារបស់ព្រះគ្រីស្តផង និងក៏ជាឱកាសឱ្យអំណរសប្បាយរបស់ខ្លួនបានពេញលក្ខណៈផងដែរ ។

## យុវវ័យជួយស្ត្រីដូចជួយខ្លួនឯង និងសង្គមជាតិ (បទពាក្យប្រាំពីរ)



១. មើលប្រធានបទកំណត់ជាក់ គួរតែនួនអ្នកពិចារណា
អក្ខរាចារពិតជិតបដា យុវនោះណាំជួយខ្លួនឯង ។
២. ការជួយខ្លួនឯងពិសេសណាស់ ភាពពិតឃើញច្បាប់គ្រប់កន្លែង
ញៀនគ្រប់ប្រភេទអេដស៍ជាក់ស្តែង កុំឈ្លក់វង្វេងល្បែងតណ្ហា ។
៣. ជួយខ្លួនឯងបានប្រាណសោយសុខ បាបកម្មគ្រប់មុខទុក្ខបញ្ហា
នឹងរលាយឯងស្វែងយ៉ាងណា ប៉ុនប៉ងប្រាថ្នាមិនជួយឡើយ ។
៤. ដូចជួយស្ត្រីស្តីថ្លែងថា តភ្ជាប់អក្ខរារួចទៅហើយ
លើកស្ទួយស្ត្រីកុំកន្តើយ ស្ត្រីនេះហើយជាឆ្អឹងខ្នង ។
៥. មានសាច់មានឈាមមានខ្លួនប្រាណ មានគ្រប់សណ្ឋានតាមកន្លង
ដៃជើងមុខមាត់ដូចបំណង បើគ្មានឆ្អឹងខ្នងរស់មិនបាន ។
៦. ដូចជាមនុស្សស្លាប់មួយកំណាត់ ដាច់ដោចបោចបាត់ចេញពីប្រាណ
កណ្តោចកណ្តែងថ្លែងហួសស្មាន ស្រវាំសុខសាន្តជួបតែទុក្ខ ។
៧. ពាក្យជួយខ្លួនឯងតែងតែឈ្នះ រៀងរាល់ជំនះព្រះឱ្យសុខ
ដូចជួយស្ត្រីភ័យមានទុក្ខ អ្នកជួបតែសុខគ្រប់ប្រការ ។
៨. ២០១១ ស្ទួលវិស័យ ប្អូនយុវវ័យស្រីប្រុសណាំ
ជាសសរទ្រូងមាំអស្ចារ្យ បំរើរដ្ឋាសង្គមជាតិ ។
៩. កើតជាកូនខ្មែរថៃពូជពង្ស មរតកយូរលង់កុំបីឃ្លាត
ប្រពៃណីល្អបវរទៀត ភ្ញៀវអន្តរជាតិកោតសរសើរ ។
១០. កូនខ្មែរជួយខ្មែរដោយស្មោះសរ ឧក្រិដ្ឋមិនល្អបន្តស្មើ
បញ្ឈប់បញ្ចប់កប់ប្រសើរ ជាតិធ្វើដំណើរអភិវឌ្ឍន៍ ។

**និពន្ធដោយ : លោកស្រី ខុន ណារី**
**ថ្ងៃទី១៧ មីនា ២០១១**

# ទទួលជំហានទី២ នៅព្រះសហគមន៍ភ្នំពេញ និងបាត់ដំបង

លី សុវណ្ណា

















## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

# លេខទូរស័ព្ទដែលត្រូវហៅ បន្ទាន់

***ប៉ូលីស :**

១១៧

-ប៉ូលីសចរាចរណ៍ ០១២ ៨៩៦ ៦២៨។

***រថយន្តសង្គ្រោះបន្ទាន់ :**

១១៩ / ០២៣ ៧២៣ ៨៤០។

-ភ្នំពេញ ០២៣ ៧២៤ ៨៩១។ -សៀមរាប ០៦៣ ៧៦១ ១១៩។

***ក្រុមពន្លត់អគ្គីភ័យ :**

១១៨ / ០២៣ ៧២៣ ៥៥៥។

***មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :**

០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩។

---

# វិទ្យុវ៉េរីតាស់អាស៊ី (RVA)

Radio Veritas Asia
Crossing Borders, Sharing Christ

**ផ្នែកភាសាខ្មែរផ្សាយរយៈពេល ៣០នាទី ជារៀងរាល់ថ្ងៃតាមរយៈរលកធាតុអាកាសខ្លី (Short Wave = sw) គឺ :**

-ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស ១១៨៥០ គីឡូហឺតស៏ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្ដាប់វិទ្យុវ៉ារីតាស់ អាស៊ី (RVA)

លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃ និងសង្គម និងព័ត៏មាននានាពីព្រះសហគមន៏កាតូលិកនៅកម្ពុជា។

---

*ការិយាល័យផ្សព្វផ្សាយព័ត៏មានកាតូលិក*

*មានផលិតជា ឌីវីឌី រឿងសន្ត សន្ដិផ្សេងៗ និងកម្មវិធីបុណ្យផ្សេងៗ ដូចជាសម្ពោធភ្នំព្រះនាងម៉ារី នៅចំការទៀង ពិធីប្រោះព្រំភូមិនៅព្រះសហគមន៏ចំណោម បាត់ដំបង... ហើយថ្មីៗនេះយើងខ្ញុំក៏មានចេញលក់នូវស៊ីឌីចម្រៀងថ្មី CD Vol.13 ។ ដូច្នេះបើប្រិយមិត្តចាប់អារម្មណ៏ សូមអញ្ជើញទាក់ទងមកលេខទូរស័ព្ទ ០៩៩ ៩៩៩ ៨៦៥។*

*សូមអរគុណ !*

---

# ការងារប្រចាំខែ

- ថ្ងៃទី០១-០៤ មេសា ២០១១ : សិក្ខាសាលាគ្រូអប់រំជំនឿលើប្រធានបទកំណើតព្រះបន្ទូលនៅព្រះសហគមន៏កោះរកា កំពង់ចាម។
- ថ្ងៃទី០២ មេសា ២០១១ : កម្មវិធីសំណាក់ធម៏ ដែលមានការអញ្ជើញចូលរួមណែនាំពីលោកអភិបាលអូលីវីយេ ឆ្មិតអីស្លែរ ដល់គ្រីស្ដបរិស័ទនៅព្រះសហគមន៏កាតូលិកកំពត។
- ថ្ងៃទី០៣ មេសា ២០១១ : សំណាក់ធម៏ដែលមានការអញ្ជើញចូលរួមពីលោកអភិបាលអូលីវីយេ ឆ្មិតអីស្លែរ ធ្វើការណែនាំដល់គ្រីស្ដបរិស័ទនៅព្រះសហគមន៏ជុំគិរី កំពត។
- ថ្ងៃទី០៤-០៩ មេសា ២០១១ : សិក្ខាសាលាប្រជុំប្រធានក្រុមយុវជនភូមិភាគភ្នំពេញលើប្រធានបទ “យុវជន និងភាពជាអ្នកដឹកនាំ” ដែលរៀបចំធ្វើឡើងនៅព្រះសហគមន៏កាតូលិកក្រុងព្រះសីហនុ។
- ថ្ងៃទី០៧ មេសា ២០១១ : ព្រះសហគមន៏មួយចំនួននៅខេត្តតាកែវ និងខេត្តកំពត ដូចជាគិរីវង្ស និងកំពត មានរៀបចំកម្មវិធីប្រកួតកីឡាបាល់ទាត់ បាល់ទោះ នៅភូមិចំការទៀង ឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ។
- ថ្ងៃទី០៧-០៩ មេសា ២០១១ : កម្មវិធីសំណាក់ធម៏សម្រាប់អ្នកត្រៀមទទួលពិធីជ្រមុជទឹកនៅព្រះសហគមន៏កំពង់ចាម និងកោះរកា។
- ថ្ងៃទី១០ មេសា ២០១១ : កម្មវិធីជម្រះចិត្តលើកទី៣ សម្រាប់គ្រីស្ដបរិស័ទអ្នកដែលបានទទួលជំហានទី២ នៅព្រះសហគមន៏កំពត។
- ថ្ងៃទី១៧ មេសា ២០១១ : ព្រះសហគមន៏កំពតរៀបចំកម្មវិធីបើកភ្នែកសម្រាប់គ្រីស្ដបរិស័ទ និងអ្នកដែលបានទទួលជំហានទី២។
- ថ្ងៃទី២៣-២៤ ខែមេសា : បុណ្យចម្លង និងគ្រីស្ដបរិស័ទទទួលពិធីជ្រមុជ ទឹកចំនួន ៣០នាក់នៅព្រះសហគមន៏ សៀមរាប។


## ការិយាល័យព័ត៏មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧